## ធនាគារ ព្រីនស៍ ម.ក
## បញ្ញត្តិ និងលក្ខខណ្ឌនៃផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម

បញ្ញត្តិនិងលក្ខខណ្ឌនេះ គ្រប់គ្រងលើផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ("**បញ្ញត្តិនិងលក្ខខណ្ឌ**") ត្រូវយកមកអាននិងអនុវត្តជាមួយបញ្ញត្តិនិងលក្ខខណ្ឌទូទៅដែលគ្រប់គ្រង គណនី សេវាកម្ម និងផលិតផល ("**បញ្ញត្តិនិងលក្ខខណ្ឌទូទៅ**") និង បញ្ញត្តិនិងលក្ខខណ្ឌដែលពាក់ព័ន្ធផ្សេងទៀត ដែលនឹងអាចត្រូវបានយកមកអនុវត្ត។ លោកអ្នក ត្រូវអាន យល់ និងយល់ព្រមទទួលយក នូវបញ្ញត្តិនិងលក្ខខណ្ឌនេះ មុនពេលប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ។ លោកអ្នក អាចចូលទៅមើល ឬទាញយកបញ្ញត្តិនិងលក្ខខណ្ឌនេះ ពីគេហទំព័រផ្លូវការ ឬនៅសាខាប្រតិបត្តិការណាមួយរបស់ធនាគារយើង។ ក្នុងករណីដែលលោកអ្នកមានចម្ងល់ណាមួយទាក់ទងនឹងបញ្ញត្តិនិងលក្ខខណ្ឌនេះ លោកអ្នកអាចទាក់ទងមកកាន់ធនាគារយើងតាមរយៈទូរស័ព្ទលេខ៖ **១៨០០ ២០ ៨៨៨៨** ។

នៅពេលលោកអ្នកចុះហត្ថលេខាលើពាក្យស្នើសុំប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ លោកអ្នក យល់ព្រមជាឱឡារិកក្នុងការគោរពអនុវត្តតាម បញ្ញត្តិនិងលក្ខខណ្ឌនេះ ហើយបញ្ញត្តិនិងលក្ខខណ្ឌនេះ គឺជាកិច្ចសន្យាដែលចងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ រវាងលោកអ្នក និង ធនាគារយើងខ្ញុំ ។ ប្រសិនបើមានទំនាក់ទំនងអាជីវកម្មពិសេសណាមួយរវាងលោកអ្នក និងធនាគារយើងខ្ញុំ ត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងដាច់ដោយឡែក ឬ បញ្ញត្តិនិងលក្ខខណ្ឌជាក់លាក់ណាមួយ នោះកិច្ចព្រមព្រៀង ឬបញ្ញត្តិនិងលក្ខខណ្ឌជាក់លាក់នោះ ត្រូវមានឧត្តមានុភាពលើបញ្ញត្តិនិងលក្ខខណ្ឌនេះ នៅពេលដែលមានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀង ឬបញ្ញត្តិនិងលក្ខខណ្ឌជាក់លាក់នោះ មិនស៊ីសង្វាក់ជាមួយនឹងបញ្ញត្តិនិងលក្ខខណ្ឌនេះ។ ដូចគ្នាផងដែរ ប្រសិនបើវិធានអន្តរជាតិដែលអនុវត្តចំពោះផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មនីមួយៗ មានភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងបញ្ញត្តិនិងលក្ខខណ្ឌនេះ នោះបញ្ញត្តិនិងលក្ខខណ្ឌនេះនឹងត្រូវមានឧត្តមានុភាពនៅក្នុងវិសាលភាពនៃភាពមិនស៊ីសង្វាក់គ្នានោះ។ រាល់ពាក្យបច្ចេកទេសទាំងឡាយណា ដែលមិនត្រូវបានផ្តល់និយមន័យ នៅក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវមានន័យដូចដែលបានឱ្យនិយមន័យនៅក្នុងបញ្ញត្តិនិងលក្ខខណ្ឌទូទៅ។

### ១. និយមន័យ

១.១ "**គណនី**" សំដៅលើ គណនីធនាគារនានា ដូចជាគណនីបញ្ញើសន្សំ គណនីចរន្ត ឬគណនីបញ្ញើមានកាលកំណត់ ឬគណនីផ្សេងទៀត ដែលលោកអ្នកបានបើកនិងរក្សានៅជាមួយធនាគារយើង។

១.២ "**ធនាគារប្រឹក្សា**" សំដៅលើ ធនាគារដែលផ្តល់ប្រឹក្សាលើ លិខិតធានាធនាគារ ឬលិខិតឥណទាន ឬលិខិតឥណទានប្រចាំការទៅតាមការស្នើសុំរបស់ធនាគារដែលចេញលិខិត។

១.៣ "**អ្នកតំណាងស្របច្បាប់**" សំដៅលើ រូបវន្តបុគ្គលដែលទទួលបានការអនុញ្ញាតពីលោកអ្នក តាមរយៈលិខិតស្នាមដែលមានសុពលភាព និងទទួលយកបានដោយធនាគារយើងខ្ញុំ ហើយលោកអ្នកបានជូនដំណឹងមកធនាគារយើង ថាជាអ្នកតំណាងស្របច្បាប់របស់លោកអ្នក ដើម្បីបំពេញកិច្ចនានា នៅក្នុងនាមរបស់លោកអ្នក ទាក់ទងនឹងការស្នើសុំ ឬការទទួលបានការប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ នៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ ។

១.៤ "**លិខិតធានាធនាគារ**" សំដៅលើ លិខិតសន្យាដែលត្រូវបានចុះហត្ថលេខា ហើយដែលបញ្ជាក់ពីការអះអាងក្នុងការទូទាត់ប្រាក់ក្នុងករណីទទួលបានការបង្ហាញនូវការទាមទារឱ្យទូទាត់ទឹកប្រាក់ធានាដែលត្រឹមត្រូវ ទោះបីលិខិតសន្យានេះមានឈ្មោះ ឬត្រូវបានព័ណ៌នាបែបណាក៏ដោយ។

១.៥ "**ថ្ងៃធ្វើប្រតិបត្តិការរបស់ធនាគារ**" សំដៅលើ ថ្ងៃដែលធនាគារធ្វើប្រតិបត្តិការជាទៀងទាត់ នៅទីកន្លែងដែលប្រតិបត្តិការ ឬសកម្មភាពដែលស្ថិតនៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានប្រតិបត្តិ។

១.៦ **"អ្នកទទួលផល"** សំដៅលើ បុគ្គលដែលជាអ្នកទទួលផលប្រយោជន៍ ពីការចេញលិខិតធានាធនាគារ លិខិតឥណទានប្រចាំការ លិខិតឥណទាន ឬលិខិតធានាលើការដឹកទំនិញ។

១.៧ **"រូបិយាណត្តិ"** សំដៅលើ ការបញ្ជាជាលាយលក្ខណ៍អក្សរដោយឥតលក្ខខណ្ឌ ចេញដោយបុគ្គលមួយ ជូនទៅបុគ្គលម្នាក់ទៀត ដែលបានចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យបុគ្គលជាអ្នកទទួលបញ្ជា ទូទាត់សងចំនួនទឹកប្រាក់ជាក់លាក់មួយឱ្យទៅ ឬតាមបញ្ជារបស់បុគ្គលមួយទៀត ឬអ្នកកាន់។ រូបិយាណត្តិ អាចត្រូវបានទូទាត់ភ្លាមៗ ឬនៅកាលបរិច្ឆេទឥណប្រតិទាន។

១.៨ **"ទ្រព្យធានា"** សំដៅលើ គណនីធនាគារដែលត្រូវបានបើកនិងរក្សាជាមួយធនាគារយើងខ្ញុំ ឬចលនវត្ថុ ឬអចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់លោកអ្នក និង/ឬរបស់តតិយជនណាមួយ ដែលត្រូវបានប្រើប្រាស់ជាប្រាតិភោគ ធានាលើការអនុវត្តកាតព្វកិច្ចទាំងអស់របស់លោកអ្នក ដែលមានទាក់ទងនឹងការផ្តល់ផលិតផលឬសេវាហិរញ្ញប្បទានពាណិជ្ជកម្មរបស់ធនាគារយើង ទៅតាមការស្នើសុំរបស់លោកអ្នក។

១.៩ **"ធនាគារប្រមូល"** សំដៅលើ ធនាគារដែលមិនមែនជាធនាគារផ្ញើ ហើយដែលទាក់ទងនឹងសេវាប្រមូលឯកសារ។

១.១០ **"ការទាមទារឱ្យទូទាត់ប្រាក់"** សំដៅលើ ឯកសារដែលត្រូវបានចុះហត្ថលេខាដោយអ្នកទទួលផល ទាមទារឱ្យធ្វើការទូទាត់ប្រាក់នៅក្រោមលិខិតធានាធនាគារ។

១.១១ **"គណនីដែលត្រូវបានកំណត់"** សំដៅលើ គណនីធនាគាររបស់លោកអ្នក រួមមាន គណនីបញ្ញើសន្សំ ឬគណនីចរន្ត ដែលបានបើកនិងរក្សាទុកជាមួយធនាគារយើង ដូចមានបញ្ជាក់ក្នុងពាក្យស្នើសុំ ឬដែលលោកអ្នកបានជូនដំណឹងមកកាន់ធនាគារយើង ដែលតាមរយៈនោះ លោកអ្នកយល់ព្រមដោយឥតលក្ខខណ្ឌ និងដោយមិនអាចដកហូតវិញបាន អនុញ្ញាតឱ្យធនាគារយើងកាត់ប្រាក់សម្រាប់ធ្វើការទូទាត់ប្រាក់ដែលនឹងត្រូវធ្វើ ឬត្រូវបានធ្វើឡើង នៅក្រោមផលិតផល និងសេវាហិរញ្ញប្បទានពាណិជ្ជកម្មដែលលោកអ្នកបានស្នើសុំ រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ ការទូទាត់ប្រាក់ទៅកាន់អ្នកទទួលផល ឬអ្នកទទួលប្រាក់ផ្សេងទៀត (ទៅតាមករណីជាក់ស្តែង) ការទូទាត់កម្រៃសេវាដែលពាក់ព័ន្ធ ការទូទាត់ប្រាក់ថ្លៃចំណាយផ្សេងៗ និងការចំណាយដែលបានកើនឡើងនានា ។

១.១២ **"ឯកសារ"**

ក. សម្រាប់លិខិតធានាធនាគារៈ ឯកសារ សំដៅលើ កំណត់ត្រានៃព័ត៌មាន នៅក្នុងទម្រង់ជាក្រដាស ឬអេឡិចត្រូនិក ដែលត្រូវបានចុះហត្ថលេខា ឬមិនមានចុះហត្ថលេខា និងដែលអាចផលិតជាថ្មីបាន នៅក្នុងទម្រង់ដែលមើលឃើញដោយបុគ្គលដែលឯកសារនោះត្រូវបានបង្ហាញ។ ឯកសារ រួមមាន លិខិតទាមទារឱ្យទូទាត់ទឹកប្រាក់ធានា និងសេចក្តីថ្លែងគាំទ្រនានា (ទៅតាមករណីជាក់ស្តែង)។

ខ. សម្រាប់សេវាប្រមូលឯកសារៈ ឯកសារ សំដៅលើ ឯកសារហិរញ្ញវត្ថុ និង/ឬ ឯកសារពាណិជ្ជកម្មៈ

i. ឯកសារហិរញ្ញវត្ថុ សំដៅលើ រូបិយាណត្តិ ប័ណ្ណសងតាមបញ្ជា មូលប្បទានប័ត្រ ឬឧបករណ៍ដែលមានលក្ខណៈប្រហាក់ប្រហែល ដែលត្រូវបានប្រើប្រាស់ដើម្បីទទួលបានការទូទាត់ប្រាក់។

ii. ឯកសារពាណិជ្ជកម្ម សំដៅលើ វិក្កយបត្រ ឯកសារដឹកជញ្ជូនទំនិញ ឯកសារបញ្ជាក់សិទ្ធិ ឬឯកសារដែលមានលក្ខណៈប្រហាក់ប្រហែល ឬឯកសារដទៃផ្សេងទៀត ដែលមិនមែនជាឯកសារហិរញ្ញវត្ថុ។

១.១៣ **"សេវាប្រមូលឯកសារ"** សំដៅលើ សេវារបស់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងការប្រមូលឯកសារ អនុលោមតាមសេចក្តីណែនាំឱ្យប្រមូលឯកសារដែលបានទទួល ដើម្បីៈ

ក. ទទួលបាននូវការទូទាត់ប្រាក់ភ្លាម និង/ឬ ការធ្វើស្វីការទទួលយកឯកសារដើម្បីទទួលបានការទូទាត់ប្រាក់នៅពេលកំណត់មួយ

ខ. ប្រគល់ឯកសារ ជាថ្នូរនឹងការទទួលបានការទូទាត់ប្រាក់ភ្លាម និង/ឬការធ្វើស្វីការទទួលយកឯកសារដើម្បីទទួលបានការទូទាត់ប្រាក់នៅពេលកំណត់មួយ ឬ

គ. ប្រគល់ឯកសារ ដោយមានភ្ជាប់លក្ខខណ្ឌផ្សេងៗ។

១.១៤ **"អ្នកបង់ប្រាក់"** សំដៅលើ បុគ្គលដែលត្រូវបានបង្ហាញឯកសារ ដោយអនុលោមតាមសេចក្តីណែនាំឱ្យប្រមូលឯកសារ។

១.១៥ **"លិខិតឥណទាននាំចេញ"** សំដៅលើ វិធីទូទាត់ប្រាក់ដែលត្រូវបានប្រើប្រាស់ជាទូទៅ ក្នុងប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ ដែលតាមរយៈនោះ ធនាគារយើងយល់ព្រមផ្តល់ប្រឹក្សាជូនលោកអ្នកដែលជាអ្នកទទួលផល បន្ទាប់ពីធនាគារយើងបាន ទទួលលិខិតឥណទាននាំចេញនោះពីធនាគារចេញលិខិត។

១.១៦ **"សំណុំឯកសារហិរញ្ញប្បទាន"** សំដៅលើ លិខិតផ្តល់ឥណទាន កិច្ចសន្យាខ្ចីបរិភោគរួមជាមួយឯកសារភ្ជាប់ សំណុំឯកសារ ប្រាតិភោគ និងឯកសារឯទៀតដែលត្រូវបានចុះហត្ថលេខា/ផ្តិតស្នាមម្រាមដៃ និង/ឬបញ្ជូនមកកាន់ធនាគារយើង ដោយ លោកអ្នក អ្នកបង្កើតហ៊ីប៉ូតែក អ្នកដាក់ទ្រព្យធានាបំណុល អ្នកបង្កើតសិទ្ធិលើការបញ្ចាំ និង/ឬ អ្នកធានា ដើម្បីទទួលបាន និង/ឬ ប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ដូចបានតម្រូវដោយធនាគារយើង។

១.១៧ **"ករណីប្រធានសក្តិ"** សំដៅលើ សកម្មភាពរបស់ព្រះ កុប្បកម្ម អគ្គិភ័យ ភាពវឹកវរក្នុងសង្គម សង្គ្រាម សកម្មភាពភេរវកម្ម ជំងឺ រាតត្បាត គ្រោះធម្មជាតិ ឬមូលហេតុណាមួយ ដែលហួសពីការគ្រប់គ្រងរបស់ធនាគារយើង និងដែលកាត់ផ្តាច់អាជីវកម្មរបស់ ធនាគារដែលទាក់ទងនឹង ការអនុវត្តកាតព្វកិច្ចរបស់ធនាគារ ដែលមាននៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

១.១៨ **"ទឹកប្រាក់ធានា"** សំដៅលើ ចំនួនទឹកប្រាក់ដូចមានបញ្ជាក់នៅក្នុងលិខិតធានាធនាគារ ដែលធនាគារយើងត្រូវទូទាត់ជូនអ្នក ទទួលផល បន្ទាប់ពីធនាគារយើងបានទទួលការទាមទារឱ្យទូទាត់ប្រាក់ ដែលមានលក្ខខណៈត្រឹមត្រូវ។

១.១៩ **"សេវាប្រមូលឯកសារនាំចូលទំនិញ"** សំដៅលើ របៀបទូទាត់ប្រាក់ដែលអ្នកនាំទំនិញចេញបានផ្ទុកផ្តាក់ធនាគារផ្ញើរបស់ខ្លួន ឱ្យធ្វើការបង្ហាញឯកសារមកកាន់ធនាគារយើង ដោយបញ្ជាឱ្យធនាគារយើងដែលជាធនាគារប្រមូល ឱ្យធ្វើការប្រមូលការ ទូទាត់ប្រាក់ពីលោកអ្នកដែលជាអ្នកនាំចូលទំនិញ។

១.២០ **"លិខិតឥណទាននាំចូល"** សំដៅលើ របៀបទូទាត់ប្រាក់ដែលត្រូវបានប្រើនៅក្នុងប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ ដែលតាមរយៈ នោះ ធនាគារយើងសន្យាធ្វើការទូទាត់ប្រាក់ទៅកាន់អ្នកទទួលផល(អ្នកនាំចេញទំនិញ) បន្ទាប់ពីធនាគារយើងបានទទួលការ បង្ហាញឯកសារដែលត្រឹមត្រូវពីអ្នកទទួលផល។

១.២១ **"ធនាគារចេញលិខិត"** សំដៅលើ ធនាគារដែលចេញលិខិតឥណទាន លិខិតឥណទានប្រចាំការ ឬលិខិតធានាធនាគារ ទៅ តាមការស្នើសុំរបស់អ្នកដាក់ពាក្យស្នើសុំ។

១.២២ **"វិធាន ISP 98"** សំដៅលើ វិធានរួមរបស់សភាពាណិជ្ជកម្មអន្តរជាតិស្តីពី International Standby Practices 1998 រួមទាំង វិសោធនកម្មជាបន្តបន្ទាប់ទៅលើវិធានរួមនេះ ដែលមានសុពលភាពអនុវត្ត នៅកាលបរិច្ឆេទនៃការចេញលិខិតឥណទានប្រចាំការ ដែលពាក់ព័ន្ធ។

១.២៣ **"ការចរចារ"** សំដៅលើ ការទិញរូបិយាណត្តិ (ដែលត្រូវទូទាត់ដោយធនាគារផ្សេងក្រៅពីធនាគារដែលត្រូវបានតែងតាំង) ដោយ ធនាគារដែលត្រូវបានតែងតាំង និង/ឬ ឯកសារដែលមាននៅក្រោមការបង្ហាញឯកសារដែលត្រឹមត្រូវ ដោយការផ្តល់បុរេប្រទាន ឬយល់ព្រមផ្តល់បុរេប្រទានទៅកាន់អ្នកទទួលផល នៅមុនឬនៅកាលបរិច្ឆេទជាថ្ងៃធ្វើប្រតិបត្តិការរបស់ធនាគារ ដែលការ ទូទាត់សងប្រាក់គ្រឡប់ត្រូវដល់កំណត់ទូទាត់ ចំពោះធនាគារដែលត្រូវបានតែងតាំង។

១.២៤ **"ធនាគារដែលត្រូវបានតែងតាំង"** ត្រូវមានអត្ថន័យ ដូចមានកំណត់ក្នុងវិធានរួម UCP 600 ដែលតាមរយៈនោះ ធនាគារដែល ត្រូវបានតែងតាំង សំដៅលើ ធនាគារដែលលិខិតឥណទាន ឬលិខិតឥណទានប្រចាំការ អាចត្រូវបានប្រើប្រាស់ជាមួយ ឬជា ធនាគារដែល លិខិតឥណទាន ឬលិខិតឥណទានប្រចាំការ អាចប្រើប្រាស់ជាមួយធនាគារឯទៀតបាន។

១.២៥ **"ការបង្ហាញឯកសារ"** សំដៅលើ ការប្រគល់/បញ្ជូនឯកសារ នៅក្រោម លិខិតឥណទាន ឬលិខិតឥណទានប្រចាំការ ឬលិខិត ធានាធនាគារ ទៅកាន់ធនាគារចេញលិខិត ឬធនាគារដែលត្រូវបានតែងតាំង ឬ ឯកសារដែលត្រូវបានបញ្ជូនទាំងនោះ។

១.២៦ **"ធនាគារបង្ហាញ"** សំដៅលើ ធនាគារប្រមូល ដែលធ្វើការបង្ហាញឯកសារទៅកាន់អ្នកបង់ប្រាក់ នៅក្នុងប្រតិបត្តិការនៃសេវា ប្រមូលឯកសារ។

១.២៧ **"ធនាគារផ្ញើ"** សំដៅលើ ធនាគារដែលអ្នកនាំទំនិញចេញ បានផ្ទុកផ្តាក់ឱ្យដំណើរការសេវាប្រមូលឯកសារ។

១.២៨ **"ទូទាត់សងប្រាក់"** មានន័យថា៖

ក. ការទូទាត់ប្រាក់ភ្លាមៗនៅពេលទទួលបានឯកសារ ប្រសិនបើលិខិតឥណទានអាចត្រូវបានទូទាត់នៅពេលទទួល បានឯកសារ

ខ. ការសន្យាធ្វើការទូទាត់ប្រាក់នៅកាលបរិច្ឆេទនៃឥណប្រតិទាន ប្រសិនបើលិខិតឥណទានអាចត្រូវបានទូទាត់នៅពេលក្រោយ

គ. ការធ្វើស៊ីការទទួលយករូបិយាណត្តិ ដែលត្រូវទាមទារឱ្យទូទាត់ដោយអ្នកទទួលផល និងធ្វើការទូទាត់នៅកាលបរិច្ឆេទនៃឥណប្រតិទាន ប្រសិនបើលិខិតឥណទានអនុញ្ញាតឱ្យមានការធ្វើស៊ីការ។

១.២៩ **"លិខិតធានាលើការដឹកទំនិញ"** សំដៅលើ ការធានាជាលាយលក្ខណ៍អក្សរ ចេញដោយធនាគារយើង ដែលត្រូវទទួលខុសត្រូវរួមគ្នាជាមួយអ្នកត្រូវទទួលទំនិញ ក្នុងចំនួនទឹកប្រាក់អតិបរមាដូចមានចែងក្នុងលិខិតធានាលើការដឹកទំនិញ ដើម្បីទូទាត់ប្រាក់ទៅកាន់អ្នកដឹកទំនិញ ឬភ្នាក់ងាររបស់អ្នកដឹកទំនិញ ដើម្បីឱ្យអ្នកត្រូវទទួលទំនិញដូចមានកំណត់ក្នុងលិខិតធានានេះ អាចទទួលយកការប្រគល់ទំនិញ ដែលជាកម្មវត្ថុនៃលិខិតឥណទានដែលពាក់ព័ន្ធដែលធនាគារយើងបានចេញ ដោយមិនចាំបាច់បង្ហាញឯកសារដឹកទំនិញ ដែលមានតម្រូវនៅក្នុងលិខិតឥណទាននោះ។

១.៣០ **"ឥណទានហិរញ្ញប្បទានពាណិជ្ជកម្ម"** សំដៅលើ ឥណទានមានកាលកំណត់ដែលធនាគារយើងផ្តល់ជូនលោកអ្នក ទៅតាមការស្នើសុំរបស់លោកអ្នក ដើម្បីគាំទ្រសកម្មភាព នាំចូល/ចេញ ឬទិញ/លក់ ទំនិញជាក់លាក់របស់លោកអ្នក ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវចរន្តសាច់ប្រាក់របស់លោកអ្នក ដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌនេះ និងបញ្ញត្តិនៃសំណុំឯកសារហិរញ្ញប្បទាន។

១.៣១ **"ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម"** សំដៅលើ លិខិតធានាធនាគារ លិខិតឥណទាន លិខិតឥណទានប្រចាំការ សេវាប្រមូលឯកសារ លិខិតធានាលើការដឹកទំនិញ ឥណទានហិរញ្ញប្បទានពាណិជ្ជកម្ម និងផលិតផលនិងសេវាឯទៀតដែលពាក់ព័ន្ធនឹងហិរញ្ញប្បទានពាណិជ្ជកម្ម ដូចដែលត្រូវបានផ្តល់ជូនដោយធនាគារយើងពីពេលមួយទៅពេលមួយ។

១.៣២ **"កិច្ចសន្យាចំបង"** ឬ **"ប្រតិបត្តិការចំបង"** សំដៅលើ កិច្ចសន្យា ប្រតិបត្តិការ លក្ខខណ្ឌនៃការដេញថ្លៃ ឬទំនាក់ទំនងផ្សេងទៀតរវាងលោកអ្នក និងអ្នកទទួលផល ជាមូលដ្ឋានដែលលិខិតធានាធនាគារ ឬលិខិតឥណទាន ឬលិខិតឥណទានប្រចាំការ ត្រូវបានចេញ។

១.៣៣ **"វិធានរួម UCP 600"** សំដៅលើ វិធានរួមសម្រាប់ឯកសារឥណទានរបស់សភាពាណិជ្ជកម្មអន្តរជាតិ (ឬវិធានបន្ថែម ការកែប្រែ វិសោធនកម្ម ការជំនួសវិធានរួមនោះ) ដែលមានជាធរមាននៅកាលបរិច្ឆេទនៃការចេញលិខិតឥណទាន ឬលិខិតឥណទានប្រចាំការ។

១.៣៤ **"វិធានរួម URC 522"** សំដៅលើវិធានរួមរបស់សភាពាណិជ្ជកម្មអន្តរជាតិសម្រាប់សេវាប្រមូលឯកសារ (ឬវិធានបន្ថែម ការកែប្រែ វិសោធនកម្ម ឬការជំនួសវិធានរួមនោះ) ដែលមានជាធរមាននៅកាលបរិច្ឆេទដែលសេវាប្រមូលឯកសារត្រូវបានប្រតិបត្តិ។

១.៣៥ **"វិធានរួម URDG 758"** សំដៅលើ វិធានរួមរបស់សភាពាណិជ្ជកម្មអន្តរជាតិសម្រាប់លិខិតធានាធនាគារ (ឬវិធានបន្ថែម ការកែប្រែ វិសោធនកម្ម ឬការជំនួសវិធានរួមនោះ) ដែលមានជាធរមាននៅកាលបរិច្ឆេទនៃការចេញលិខិតធានាធនាគារ។

## ២. ផលិតផល និងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងការស្នើសុំ

២.១ យោងតាមការស្នើសុំរបស់លោកអ្នក ធនាគារយើងអាចផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ជូនលោកអ្នកប្រើប្រាស់ ទៅតាមឆន្ទានុសិទ្ធិរបស់ធនាគារយើងខ្ញុំ និងដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌនេះ មានដូចជា៖ លិខិតធានាធនាគារ លិខិតឥណទានប្រចាំការ លិខិតឥណទាន លិខិតធានាលើការដឹកទំនិញ សេវាប្រមូលឯកសារ និងឥណទានហិរញ្ញប្បទានពាណិជ្ជកម្ម។

### ២.២. លិខិតធានាធនាគារ

២.២.១. លិខិតធានាធនាគារនីមួយៗ ដែលត្រូវបានចេញជូនលោកអ្នកដោយធនាគារយើង ទៅតាមការស្នើសុំរបស់លោកអ្នក ត្រូវតែស្ថិតក្រោមការអនុវត្តនៃវិធានរួម URDG 758។

២.២.២. នៅពេលដែលលោកអ្នកស្នើសុំធនាគារយើងខ្ញុំ ឱ្យចេញលិខិតធានាធនាគារ សម្រាប់ជាប្រយោជន៍ដល់អ្នកទទួលផលណាមួយ លោកអ្នកយល់ព្រមគោរពតាមបញ្ញត្តិនិងលក្ខខណ្ឌខាងក្រោម៖

ក. លោកអ្នក ត្រូវដាក់ជូនធនាគារយើងខ្ញុំនូវពាក្យស្នើសុំ នៅក្នុងទម្រង់ដែលត្រូវបានកំណត់ដោយធនាគារយើង រួមជាមួយព័ត៌មាននិងឯកសារទាំងអស់ ដែលត្រូវបានតម្រូវដោយធនាគារយើងខ្ញុំ នៅក្នុងពាក្យស្នើសុំនោះ ឬនៅពេលក្រោយ។ លិខិតធានាធនាគារ ដែលចេញដោយធនាគារយើង ត្រូវមានអានុភាពអនុវត្តនៅពេលដែល

ឯកសារច្បាប់ដើមនៃលិខិតនោះ ត្រូវបានចុះហត្ថលេខានិងប្រថាប់ត្រាដោយធនាគារយើង ឬនៅកាលបរិច្ឆេទដូចមានកំណត់នៅក្នុងលិខិតនោះ ឬនៅកាលបរិច្ឆេទនៃការចេញលិខិតធានាធនាគារក្នុងករណីលិខិតនោះមិនមានចែងពីកាលបរិច្ឆេទប្រសិទ្ធិភាពជាក់លាក់ណាមួយ និងត្រូវបន្តមាន សុពលភាពសម្រាប់រយៈពេលសុពលភាព ឬរហូតដល់កាលបរិច្ឆេទផុតសុពលភាព ដូចមានកំណត់ក្នុងលិខិតធានានោះ ឬរហូតដល់ពេលដែលលិខិតធានាធនាគារត្រូវបានបញ្ចប់សុពលភាពដូចមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

ខ. អ្នកទទួលផលនៃលិខិតធានាធនាគារ ត្រូវទទួលរ៉ាប់រង នូវរាល់ហានិភ័យដែលទាក់ទងនឹងសកម្មភាព ឬ អកម្មភាពរបស់ខ្លួន និងរបស់អ្នកប្រើប្រាស់ណាមួយនៃលិខិតធានាធនាគារ រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ ករណីខាងក្រោម៖

  i. ការប្រើប្រាស់ដោយមិនត្រឹមត្រូវនៃលិខិតធានាធនាគារ ឬ

  ii ទម្រង់ ភាពគ្រប់គ្រាន់ ភាពត្រឹមត្រូវ ការក្លែងបន្លំ និងភាពស្របច្បាប់នៃព័ត៌មាននិងឯកសារទាំងអស់ដែលត្រូវបានបង្ហាញមកកាន់ធនាគារយើង។

ដើម្បីបញ្ចៀសរាល់ភាពសង្ស័យ អ្នកទទួលផលត្រូវបានចាត់ទុកថា បានបញ្ជាក់យល់ព្រមថា ការទាមទារឱ្យទូទាត់ទឹកប្រាក់ធានាដែលត្រូវបានបង្ហាញមកកាន់យើងខ្ញុំ ត្រូវបានធ្វើឡើងដោយសុចរិត និងមិនមានចេតនាអាក្រក់ឬទុច្ចរិតណាមួយឡើយ។

គ. ការទាមទារឱ្យទូទាត់ប្រាក់នៅក្រោមលិខិតធានាធនាគារ ត្រូវដាក់ជូនធនាគារយើងជាលាយលក្ខណ៍អក្សរ ក្នុងទម្រង់ជាក្រដាសច្បាប់ដើម និងត្រូវមានចុះហត្ថលេខាដោយអ្នកទទួលផល ឬតំណាងស្របច្បាប់របស់អ្នកទទួលផលប្រសិនបើអ្នកទទួលផលជានីតិបុគ្គល។ ការទាមទារឱ្យទូទាត់ប្រាក់ ត្រូវមានភ្ជាប់ជាមួយដោយសេចក្តីថ្លែងគាំទ្រការទាមទារនោះ និងឯកសារនានាដូចមានកំណត់ក្នុងលិខិតធានាធនាគារ។ ការបង្ហាញការទាមទារនីមួយៗ ត្រូវមានការចង្អុលបង្ហាញនូវព័ត៌មានលម្អិតរបស់លិខិតធានាធនាគារ ដែលជាមូលដ្ឋាននៃការទាមទារនោះ រួមបញ្ចូលនិងមិនកម្រិតត្រឹមតែ លេខយោង និងកាលបរិច្ឆេទនៃលិខិតធានាធនាគារ។ ការបង្ហាញឯកសារមកកាន់ធនាគារយើង ត្រូវធ្វើឡើងនៅការិយាល័យប្រតិបត្តិការរបស់ធនាគារយើង ឬនៅទីតាំងផ្សេងទៀត និងត្រូវធ្វើឡើង នៅឬមុនកាលបរិច្ឆេទផុតសុពលភាពដូចមានកំណត់ក្នុងលិខិតធានាធនាគារ។ បន្ទាប់ពីធនាគារយើង បានទទួលការទាមទារឱ្យទូទាត់ប្រាក់ នៅក្រោមលិខិតធានាធនាគារពីអ្នកទទួលផល លោកអ្នកយល់ព្រមថា ធនាគារយើងមានសិទ្ធិត្រួតពិនិត្យលើការទាមទារនោះ និងមានសិទ្ធសម្រេចទៅតាមសុភវិនិច្ឆ័យរបស់ខ្លួន លើអនុលោមភាព ឬភាពត្រឹមត្រូវនៃការទាមទារនោះ។

ឃ. ក្នុងករណីដែលធនាគារយើងទទួលបានការទាមទារឱ្យទូទាត់ប្រាក់ដែលមានលក្ខណៈមិនត្រឹមត្រូវ ធនាគារយើងមានសិទ្ធិបដិសេធការទាមទារនោះ តាមឆន្ទានុសិទ្ធិតែមួយគត់របស់ធនាគារយើង ដោយធ្វើការជូនដំណឹងស្តីពីការបដិសេធនោះ ជាមួយនឹងមូលហេតុអប្បបរមានៃការបដិសេធនោះ មានដូចជា ភាពមិនស៊ីសង្វាក់គ្នារវាងទំហំទឹកប្រាក់ដែលអាចទាមទារបាន និងចំនួនទឹកប្រាក់ជាក់ស្តែងដែលអ្នកទទួលផលបានទាមទារ។ ការទាមទារឱ្យទូទាត់ប្រាក់មួយ មានលក្ខណៈមិនត្រឹមត្រូវ ប្រសិនបើ៖

  i. ទឹកប្រាក់ទាមទារមានចំនួនច្រើនជាង ទំហំទឹកប្រាក់ដែលអាចទាមទារបាន នៅក្រោមលិខិតធានាធនាគារ ឬ

  ii. សេចក្តីថ្លែងគាំទ្រការទាមទារ ឬឯកសារដែលបានតម្រូវដោយលិខិតធានាធនាគារ បានបង្ហាញចំនួនទឹកប្រាក់ដែលមានចំនួនសរុបតិចជាងចំនួនទឹកប្រាក់ដែលបានទាមទារ។

បន្ទាប់ពីបានជូនដំណឹងស្តីពីការបដិសេធការទាមទារប្រាក់ ដូចមានចែងក្នុងប្រការនេះ ធនាគារយើងអាចប្រគល់ ឯកសារទាមទារឱ្យទូទាត់ប្រាក់ណាមួយ ឬឯកសារណាមួយ ដែលបានបង្ហាញមកកាន់ខ្លួន នៅក្នុងទម្រង់ជាក្រដាស ត្រឡប់ទៅឱ្យបុគ្គលដែលបានបង្ហាញការទាមទារនោះវិញ ហើយអាចរក្សាទុកកំណត់ត្រាដែលពាក់ព័ន្ធ ក្នុងទម្រង់អេឡិចត្រូនិក ក្នុងរបៀបណាមួយក៏បានដែលធនាគារយើងយល់ឃើញថាសមរម្យដោយមិនមានការទទួលខុសត្រូវអ្វីទាំងអស់។

ង. ចំនួនទឹកប្រាក់ដែលជាកម្មវត្ថុនៃការទូទាត់ នៅក្រោមលិខិតធានាធនាគារ ត្រូវបានកាត់បន្ថយ ដោយ៖

i. ចំនួនទឹកប្រាក់ដែលត្រូវបានទូទាត់រួចរាល់ហើយ នៅក្រោមលិខិតធានាធនាគារ

ii. លទ្ធផលកើតចេញពីការស្នើសុំកែប្រែទំហំទឹកប្រាក់ធានានៅក្រោមលិខិតធានាធនាគារ ឬ

iii. ចំនួនទឹកប្រាក់ដែលត្រូវបានចង្អុលបង្ហាញនៅក្នុងលិខិតរួចពីការទទួលខុសត្រូវដោយផ្នែកក្រោមលិខិតធានាធនាគារ ដោយមានចុះហត្ថលេខាដោយអ្នកទទួលផល។

ច. សិទ្ធិរបស់អ្នកទទួលផលក្នុងការទាមទារឱ្យទូទាត់ប្រាក់ នៅក្រោមលិខិតធានាធនាគារ ដែលធនាគារយើងបានចេញ ត្រូវបញ្ចប់ នៅពេលដែល៖

i. ធនាគារយើង បានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរពីអ្នកទទួលផលស្តីពី ការដោះលែងធនាគារយើងឱ្យរួចពីកាតព្វកិច្ចធានាទាំងអស់ដែលមាននៅក្រោមលិខិតធានាធនាគារ។

ii. អ្នកទទួលផល និងធនាគារយើង បានយល់ព្រមបញ្ចប់សុពលភាពនៃលិខិតធានាធនាគារជាលាយលក្ខណ៍អក្សរ ដែលការព្រមព្រៀងនេះ ត្រូវតែបញ្ជាក់ដោយការចុះហត្ថលេខាដោយអ្នកទទួលផល និងធនាគារយើង។

iii. ទឹកប្រាក់ធានានៅក្រោមលិខិតធានាធនាគារ ត្រូវបានបង់ពេញលេញគ្រប់ចំនួន ឬ

iv. សុពលភាពនៃលិខិតធានាធនាគារ ដូចមានបញ្ជាក់នៅក្នុងលិខិតនោះ បានផុតសុពលភាព។

ឆ. ធនាគារយើងមានសិទ្ធិឃាត់ទុក (withhold) ការទូទាត់ប្រាក់ ប្រសិនបើមានលក្ខណៈជាក់ស្តែងនិងច្បាស់លាស់ថា៖

i. ឯកសារណាមួយមានលក្ខណៈមិនពិតប្រាកដ ឬត្រូវបានក្លែងបន្លំ។

ii. គ្មានការទូទាត់ណាមួយដែលត្រូវដល់កំណត់បង់ ផ្អែកតាមមូលដ្ឋានដែលបានលើកឡើង នៅក្នុងលិខិតទាមទារឱ្យទូទាត់ប្រាក់ ឬ

iii. ដោយពិចារណាទៅលើ ប្រភេទ និងគោលបំណងនៃលិខិតធានាធនាគារ ការទាមទារឱ្យទូទាត់ប្រាក់មិនមានមូលដ្ឋានត្រឹមត្រូវ។ ការទាមទារឱ្យទូទាត់ប្រាក់ ត្រូវចាត់ទុកថាមិនមានមូលដ្ឋានត្រឹមត្រូវ ប្រសិនបើករណីណាមួយខាងក្រោមបានកើតមានឡើង៖

ក). ហេតុការណ៍ (contingency) ឬហានិភ័យ ដែលត្រូវបានធានាដោយលិខិតធានាធនាគារ ដើម្បីជាប្រយោជន៍ដល់អ្នកទទួលផល មិនមានអត្ថិភាពពិតប្រាកដ។

ខ). កាតព្វកិច្ចចំបងរបស់អ្នកដាក់ពាក្យស្នើសុំ ត្រូវបានប្រកាសថាអសុពល ដោយតុលាការ ឬដោយមជ្ឈត្តិការ លើកលែងតែលិខិតធានាធនាគារបានគូសបញ្ជាក់ថា ហេតុការណ៍នោះស្ថិតក្នុងហានិភ័យដែលត្រូវបានធានាដោយលិខិតធានាធនាគារ។

គ). កាតព្វកិច្ចចំបង ត្រូវបានបំពេញរួចរាល់ ទៅតាមការចង់បានរបស់អ្នកទទួលផល។

ឃ). ការបំពេញកាតព្វកិច្ចចំបង ត្រូវបានហាមឃាត់ ឬរារាំង ដោយចេតនាទុច្ចរិតរបស់អ្នកទទួលផល។

ជ. ទោះបីជាលិខិតធានាធនាគារ ត្រូវបាន ឬមិនត្រូវបានប្រគល់ត្រឡប់ជូនធនាគារយើងវិញក៏ដោយ ក៏លិខិតធានាធនាគារត្រូវអស់សុពលភាព៖

i. នៅកាលបរិច្ឆេទផុតសុពលភាព

ii. នៅពេលដែលគ្មានទឹកប្រាក់ណាមួយដែលត្រូវទូទាត់ នៅក្រោមលិខិតធានាធនាគារនោះ ឬ

iii. នៅពេលមានការបង្ហាញមកកាន់ធនាគារយើង នូវលិខិតដោះលែងពីការទទួលខុសត្រូវទាំងស្រុងនៅក្រោមលិខិតធានាធនាគារ ដែលមានចុះហត្ថលេខាដោយអ្នកទទួលផល។

ឈ. នៅក្នុងករណីដែលលិខិតធានាធនាគារច្បាប់ដើម ត្រូវបានបញ្ជូនត្រឡប់មកឱ្យធនាគារយើងវិញ ដោយអ្នកទទួលផលទោះដោយមធ្យោបាយណាមួយក៏ដោយ ដើម្បីលុបចោល នៅមុនឬនៅកាលបរិច្ឆេទផុតសុពលភាពនៃលិខិតធានាធនាគារ អ្នកទទួលផលយល់ព្រមថា អ្នកទទួលផលបង្ហាញឆន្ទៈជាឱឡារិកក្នុងការលុបចោលលិខិតធានាធនាគារ ហើយអ្នកទទួលផលមិនអាចដកវិញនូវឆន្ទៈលុបចោលលិខិតធានាធនាគារនេះនាពេល

ក្រោយណាមួយឡើយបន្ទាប់ពីធនាគារយើងបានទទួលការបង្ហាញឆន្ទៈនេះរួចហើយ។ ក្នុងករណីនេះ លិខិតធានាធនាគារ ត្រូវបញ្ចប់សុពលភាពដោយស្វ័យប្រវត្តិ នៅពេលដែលធនាគារយើងបានទទួលការបង្ហាញឆន្ទៈលុបចោលលិខិតធានាធនាគារនេះ ហើយអ្នកទទួលផលយល់ព្រមលះបង់ ដោយឥតលក្ខខណ្ឌ និងដោយមិនអាចដកហូតវិញបាន នូវរាល់សិទ្ធិទាំងឡាយរបស់ខ្លួន ដែលមាននៅក្រោមលិខិតធានាធនាគារនេះ ហើយធនាគារយើងត្រូវបានដោះលែងឱ្យរួចផុតពីគ្រប់ការទទួលខុសត្រូវទាំងអស់ ដែលមាននៅក្រោមលិខិតធានាធនាគារនេះ ជារៀងរហូត។

២.២.៣. ធនាគារយើង អាចយល់ព្រមផ្តល់សេវាប្រឹក្សាលើលិខិតធានាធនាគារ ដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌខាងក្រោមនេះ ៖

ក. ធនាគារយើងអាចយល់ព្រមផ្តល់ប្រឹក្សា ឬជូនដំណឹងទៅកាន់លោកអ្នក ប្រសិនបើធនាគារយើងយល់ឃើញថា លិខិតធានាធនាគារណាមួយ ឬវិសោធនកម្មនៃលិខិតនោះ (ទៅតាមករណីជាក់ស្តែង) មានយថាភូតភាពជាក់ស្តែងទៅតាមការពេញចិត្តរបស់ធនាគារយើង។

ខ. ធនាគារយើង នឹងផ្តល់ប្រឹក្សាលើលិខិតធានាធនាគារដែលធនាគារយើងបានទទួល ដោយមិនមានផ្តល់ការអះអាង ឬការធានាបន្ថែមណាមួយ ចំពោះលោកអ្នកដែលជាអ្នកទទួលផលឡើយ។

គ. បន្ទាប់ពីទទួលបាន ការទាមទារឱ្យទូទាត់ប្រាក់ដែលមានលក្ខណៈត្រឹមត្រូវពីលោកអ្នក ធនាគារយើងអាចនឹងធ្វើការទាមទារឱ្យទូទាត់ប្រាក់នោះ នៅក្នុងនាមរបស់លោកអ្នក ទៅកាន់ធនាគារចេញលិខិត ដើម្បីទទួលបានការទូទាត់ប្រាក់នៅក្រោមលិខិតធានាធនាគារ។ បន្ទាប់ពីធនាគារយើងបានទទួលទឹកប្រាក់ពីធនាគារចេញលិខិត ធនាគារយើងនឹងផ្ទេរទឹកប្រាក់នោះ ដោយដកចេញនូវកម្រៃសេវា និងសោហ៊ុយចំណាយផ្សេងៗ ដែលទាក់ទងនឹងដំណើរការទាមទារឱ្យទូទាត់ប្រាក់ ទៅក្នុងគណនីដែលត្រូវបានកំណត់របស់លោកអ្នក។ ប៉ុន្តែប្រសិនបើ ធនាគារចេញលិខិតបដិសេធការទាមទារឱ្យទូទាត់ប្រាក់ លោកអ្នកយល់ព្រមថា ធនាគារយើងមិនមានកាតព្វកិច្ចក្នុងការផ្ទេរប្រាក់ណាមួយជូនលោកអ្នកឡើយ។

## ២.៣. លិខិតឥណទាន

២.៣.១. លិខិតឥណទាននីមួយៗ ទោះបីចេញដោយធនាគារយើង ឬដំណើរការដោយធនាគារយើង ក្នុងនាមជាធនាគារប្រឹក្សា ត្រូវអនុលោមតាមវិធានរួម UCP ៦០០។

២.៣.២. បញ្ញត្តិខាងក្រោម ត្រូវអនុវត្តក្នុងករណីដែលធនាគារយើង ចេញលិខិតឥណទាននាំចូល ទៅតាមការស្នើសុំរបស់លោកអ្នក៖

ក. បន្ទាប់ពីទទួលបានពាក្យស្នើសុំរបស់លោកអ្នក ធនាគារយើងអាចចេញលិខិតឥណទាននាំចូល សម្រាប់ជាប្រយោជន៍របស់អ្នកទទួលផល ដូចមានបញ្ជាក់នៅក្នុងពាក្យស្នើសុំ នៅក្នុងទម្រង់ដែលធនាគារយើងយល់ឃើញថាសមស្រប។ លោកអ្នកទទួលខុសត្រូវទាំងស្រុងក្នុងការធានាថា លក្ខខណ្ឌទាំងឡាយ រួមបញ្ចូលទាំងការតម្រូវនានានៃលិខិតឥណទាននាំចូលនេះ មានលក្ខណៈគ្រប់គ្រាន់។ ធនាគារយើង មិនទទួលខុសត្រូវក្នុងការផ្តល់ប្រឹក្សាជូនលោកអ្នកលើបញ្ហានេះឡើយ។

ខ. បន្ទាប់ពីលោកអ្នកបានទទួលលិខិតឥណទាននាំចូល ឬវិសោធនកម្មនៃលិខិតនោះ (ទៅតាមករណីជាក់ស្តែង) ដែលធនាគារយើងបានចេញជូនតាមការស្នើសុំរបស់លោកអ្នក លោកអ្នកត្រូវត្រួតពិនិត្យលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងលិខិតនោះដោយប្រុងប្រយ័ត្ន។ ក្នុងករណីដែលមានបញ្ហាណាមួយទាក់ទងនឹងលក្ខខណ្ឌទាំងនោះ រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ អនុលោមភាព ឬភាពស៊ីសង្វាក់គ្នាជាមួយពាក្យស្នើសុំ លោកអ្នកត្រូវជូនដំណឹងមកកាន់ធនាគារយើងក្នុងអំឡុងពេល០២(ពីរ)ថ្ងៃនៃថ្ងៃប្រតិបត្តិការធនាគារ គិតចាប់ពីថ្ងៃដែលលោកអ្នកបានទទួលលិខិតឥណទាននាំចូលនោះ បើមិនដូច្នោះទេ ត្រូវចាត់ទុកថាលោកអ្នកបានយល់ព្រមទទួលយកលក្ខខណ្ឌដូចមានចែងនៅក្នុងលិខិតឥណទាននាំចូលនោះ និង យល់ព្រមបោះបង់សិទ្ធិក្នុងការលើកឡើងនូវបញ្ហានានា ដែលទាក់ទងជាមួយលិខិតឥណទាននាំចូលនោះ។

គ. អ្នកទទួលផលនៃលិខិតឥណទាននាំចូល ត្រូវទទួលរ៉ាប់រង នូវរាល់ហានិភ័យដែលទាក់ទងនឹងសកម្មភាព ឬអកម្មភាពរបស់ខ្លួន និងរបស់អ្នកប្រើប្រាស់ណាមួយ នៃលិខិតឥណទាននាំចូល រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែករណីណាមួយដូចខាងក្រោម៖

   i. ការប្រើប្រាស់ដោយមិនត្រឹមត្រូវនៃលិខិតឥណទាននាំចូល ឬ
   ii. ទម្រង់ ភាពគ្រប់គ្រាន់ ភាពត្រឹមត្រូវ ការក្លែងបន្លំ និងភាពស្របច្បាប់នៃព័ត៌មាននិងឯកសារទាំងអស់ដែលត្រូវបានបង្ហាញមកកាន់ធនាគារយើង។

   ដើម្បីចៀសវាល់ភាពសង្ស័យ អ្នកទទួលផល ត្រូវបានចាត់ទុកថាបានបញ្ជាក់យល់ព្រមថា ការទាមទារឱ្យទូទាត់ប្រាក់ដែលត្រូវបានបង្ហាញមកកាន់ធនាគារយើង ត្រូវបានធ្វើឡើងដោយសុចរិត និងមិនមានចេតនាអាក្រក់ ឬទុច្ចរិតណាមួយឡើយ។

ឃ. លោកអ្នកយល់ព្រមថា ធនាគារយើងនឹងអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលមាននៅក្រោមលិខិតឥណទាននាំចូល ទោះមានសេចក្តីណែនាំដែលមានខ្លឹមសារផ្ទុយពីនេះ ពីលោកអ្នកក៏ដោយ។ លោកអ្នក យល់ព្រម៖

   i. ថាធនាគារយើង អាចដាក់កម្រិតលើការចរចារនៅក្រោមលិខិតឥណទាននាំចូល ត្រឹមការចរចារដោយធនាគារទំនាក់ទំនងណាមួយ ទៅតាមការជ្រើសរើសរបស់ធនាគារយើង។
   ii. ថា ផ្អែកតាមការជ្រើសរើសរបស់ខ្លួន ធនាគារយើងអាចតែងតាំងធនាគារណាមួយ ឱ្យធ្វើស្វ័ការទទួលយករូបិយាណត្តិ ឬសន្យាធ្វើការទូទាត់ប្រាក់នៅពេលក្រោយ និងអនុញ្ញាតឱ្យធនាគារដែលត្រូវបានតែងតាំងនោះ ធ្វើការទូទាត់ប្រាក់ជាមុន ឬទិញរូបិយាណត្តិដែលត្រូវបានធ្វើស្វ័ការទទួលយក ឬការសន្យាធ្វើការទូទាត់ប្រាក់នាពេលក្រោយ ដោយធនាគារដែលត្រូវបានតែងតាំងនោះ។
   iii. អនុញ្ញាតធនាគារយើងឱ្យធ្វើស្វ័ការ ទទួលយករូបិយាណត្តិទាំងអស់ ទទួលយកឯកសារ ឬការទាមទារ ឬការបង្ហាញឯកសារ ដែលត្រូវបានចុះហត្ថលេខា ឬបង្ហាញនៅក្រោមលិខិតឥណទាននាំចូលណាមួយ ក្នុងលក្ខខណ្ឌដែលការទាមទារណាមួយរបស់អ្នកទទួលផលត្រូវបានទទួលដោយធនាគារយើង នៅកាលបរិច្ឆេទ ឬនៅមុនកាលបរិច្ឆេទផុតសុពលភាពដែលអនុវត្ត ហើយគ្រប់ឯកសារ និងលក្ខខណ្ឌ ដែលតម្រូវដោយលិខិតឥណទាននាំចូល ត្រូវបានបំពេញត្រឹមត្រូវទៅតាមការចង់បានរបស់ធនាគារយើង។
   iv. ផ្អែកតាមឆន្ទានុសិទ្ធិផ្ទាល់របស់ខ្លួន ធនាគារយើងអាចធ្វើស្វ័ការទទួលយកនិងទូទាត់ ឬធ្វើស្វ័ការទទួលយកការបង្ហាញឯកសារហើយទូទាត់នៅឥណប្រតិទាន នៅពេលដែលរាល់ឯកសារដែលត្រូវបានបង្ហាញ ឬរូបិយាណត្តិដែលត្រូវបានទាមទារឱ្យទូទាត់ ឬការទាមទារឱ្យទូទាត់ប្រាក់ត្រូវបានធ្វើឡើង ស្របតាមលក្ខខណ្ឌនៃលិខិតឥណទាននាំចូល ប៉ុន្តែមិនទទួលខុសត្រូវលើរាល់ការខូចខាតដែលកើតឡើងចេញពី ឬទាក់ទងនឹង ការបដិសេធការទាមទារ ឬការបង្ហាញឯកសារណាមួយ ដោយរង់ចាំការបោះបង់របស់លោកអ្នក លើវិការៈណាមួយ ដែលមានទាក់ទងនឹងការទាមទារ ឬការបង្ហាញឯកសារនោះឡើយ។

ង. បន្ទាប់ពីបានទទួលការបង្ហាញឯកសារ នៅក្រោមលិខិតឥណទាននាំចូល ធនាគារយើងនឹងត្រួតពិនិត្យឯកសារទាំងនោះ ដោយផ្អែកលើការវិនិច្ឆ័យផ្ទាល់របស់ធនាគារយើង ហើយប្រសិនបើធនាគារយើងយល់ឃើញថា ការបង្ហាញឯកសារនេះជាការបង្ហាញដែលត្រឹមត្រូវ លោកអ្នកយល់ព្រមអនុញ្ញាតឱ្យធនាគារយើងធ្វើការទូទាត់ណាមួយ ឬធ្វើស្វ័ការទទួលយករូបិយាណត្តិ ឬការទាមទារណាមួយ នៅក្រោមលិខិតឥណទាននាំចូល ដោយមិនចាំបាច់ស្នើសុំយោបល់បន្ថែមពីលោកអ្នក ហើយទោះបីជាមានការជូនដំណឹងរបស់លោកអ្នកស្តីពីការមិនឱ្យទូទាត់ក៏ដោយ។ ប្រសិនបើធនាគារយើងយល់ឃើញថា ការបង្ហាញឯកសារមិនគោរពតាមលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងលិខិតឥណទាននាំចូល ឬដោយមូលហេតុណាមួយ៖

   i. ធនាគារយើង នឹងមិនទូទាត់ប្រាក់ចំពោះការបង្ហាញឯកសារនោះ ដោយមិនចាំបាច់ជូនដំណឹងទៅកាន់លោកអ្នក ពីការសម្រេចចិត្តរបស់ធនាគារយើង ក្នុងការមិនទទួលទូទាត់នោះឡើយ ឬ

ii. ផ្អែកតាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារយើងអាចទាក់ទងទៅកាន់លោកអ្នក ដើម្បីទទួលបានការបោះបង់ចោល នូវភាពមិនត្រឹមត្រូវនៃការបង្ហាញឯកសារពីលោកអ្នក។

២.៣.៣. ធនាគារយើង អាចប្រើប្រាស់សេវារបស់ធនាគារឯទៀត ដើម្បីផ្តល់ការប្រឹក្សាលើលិខិតឥណទាននាំចេញ និងវិសោធនកម្មណាមួយ ជូនលោកអ្នក ឬអាចធ្វើជាធនាគារប្រឹក្សានៃលិខិតឥណទាននាំចេញ និងវិសោធនកម្មនៃលិខិតឥណទាននោះ (ទៅតាមករណីជាក់ស្តែង) ដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌខាងក្រោម៖

ក. ផ្តល់ប្រឹក្សា ឬជូនដំណឹងទៅលោកអ្នក អំពីលិខិតឥណទាននាំចេញ ដែលធនាគារយើងបានទទួល និងដែលត្រូវបានចេញ សម្រាប់ជាប្រយោជន៍របស់លោកអ្នក រួមទាំងលក្ខខណ្ឌ និងវិសោធនកម្មដែលធនាគារយើងបានទទួល ទាក់ទងនឹងលិខិតឥណទាននោះ។

ខ. បង្ហាញទៅកាន់លោកអ្នក ប្រសិនបើធនាគារយើងពេញចិត្ត ចំពោះលិខិតឥណទាននាំចេញ និង/ឬវិសោធនកម្មលើលិខិតឥណទាន ទាក់ទងនឹងយថាភូតភាពជាក់ស្តែងនៃលិខិតនោះ ហើយថាការប្រឹក្សាបានឆ្លុះបញ្ចាំងពីលក្ខខណ្ឌដែលមានក្នុងលិខិតឥណទាន និង/ឬវិសោធនកម្ម ដែលបានទទួល។

គ. ផ្តល់យថាភូត និងសុពលភាព លើលិខិតឥណទាននាំចេញ នៅក្នុងនាមរបស់លោកអ្នក ឬប្រឹក្សាលើលិខិតឥណទាននាំចេញដោយមិនផ្តល់យថាភូត។

ឃ. បន្ទាប់ពីធនាគារយើង បានទទួលការស្នើសុំដែលភ្ជាប់ជាមួយឯកសារ ដែលត្រូវបានតម្រូវនៅក្រោម លិខិតឥណទាននាំចេញពីលោកអ្នក ធនាគារយើងអាចយល់ព្រមធ្វើការបង្ហាញឯកសារទៅកាន់ធនាគារចេញលិខិតនៅក្នុងនាមរបស់លោកអ្នក និងទូទាត់ប្រាក់ជូនលោកអ្នក នៅក្នុងតែករណីដែលធនាគារយើង បានទទួលការទូទាត់ប្រាក់ពីធនាគារចេញលិខិត ឬពីធនាគារទូទាត់សងប្រាក់ ដោយមិនទូទាត់សងប្រាក់ ឬចរាដោយផ្ទាល់។

ង. បន្ទាប់ពីទទួលបានមូលនិធិពីធនាគារចេញលិខិត ធនាគារយើងនឹងធ្វើការផ្ទេរមូលនិធិនេះដោយកាត់ចេញនូវកម្រៃសេវា និងសោហ៊ុយចំណាយពាក់ព័ន្ធនានា ដែលមាននៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ ទៅក្នុងគណនីដែលត្រូវបានកំណត់របស់លោកអ្នក ដែលមាននៅជាមួយធនាគារយើង។

ច. ប្រសិនបើធនាគារចេញលិខិត មិនអនុម័តទទួលយកឯកសារ និង/ឬផ្ទេរមូលនិធិ អនុលោមតាមលក្ខខណ្ឌនៃលិខិតឥណទាននាំចេញ ធនាគារយើងមិនមានកាតព្វកិច្ចផ្ទេរប្រាក់ណាមួយ ជូនលោកអ្នកឡើយ។

## ២.៤. លិខិតធានាលើការដឹកទំនិញ

២.៤.១. ក្នុងករណីដែលទំនិញត្រូវបានដឹកមកដល់ មុនការមកដល់នៃឯកសារតម្រូវ ក្រោមលិខិតឥណទាននាំចូលណាមួយដែលត្រូវបានចេញដោយធនាគារយើង (រាប់បញ្ចូលទាំងច្បាប់ដើមនៃបណ្ណដឹកជញ្ជូនទំនិញ ឬឯកសារដឹកជញ្ជូនទំនិញផ្សេងៗ) ផ្អែកលើឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារយើងអាចយល់ព្រមចេញលិខិតធានាលើការដឹកទំនិញសម្រាប់ជាប្រយោជន៍របស់ក្រុមហ៊ុនដឹកជញ្ជូន ឬអ្នកដឹកទំនិញផ្សេងទៀត តាមការស្នើសុំរបស់លោកអ្នក ដើម្បីឱ្យលោកអ្នកអាចទទួលបានទំនិញ ដែលជាកម្មវត្ថុនៃលិខិតឥណទាននាំចូល ដោយមិនមានឯកសារតម្រូវទាំងនោះ។

២.៤.២. ធនាគារយើង ត្រូវរួចផុតពីការទទួលខុសត្រូវរបស់ខ្លួន ដែលមាននៅក្រោមលិខិតធានាលើការដឹកទំនិញ៖

ក. នៅកាលបរិច្ឆេទផុតសុពលភាព ដូចមានចែងក្នុងលិខិតធានាលើការដឹកទំនិញ។

ខ. នៅពេលដែលធនាគារយើងបានទូទាត់ប្រាក់ ដូចមានចែងក្នុងលិខិតធានាលើការដឹកទំនិញ តាមការទាមទាររបស់អ្នកទទួលផលនៃលិខិតធានាលើការដឹកទំនិញ។

គ. នៅពេលមានការបង្ហាញមកកាន់ធនាគារយើង នូវលិខិតដោះលែងឱ្យរួចផុតពីការទទួលខុសត្រូវទាំងស្រុងក្រោមលិខិតធានាលើការដឹកទំនិញ ដែលមានចុះហត្ថលេខាដោយអ្នកទទួលផលនៃលិខិតធានាលើការដឹកទំនិញ។ ឬ

ឃ. នៅពេលដែលច្បាប់ដើមនៃលិខិតធានាលើការដឹកទំនិញ ត្រូវបានប្រគល់ត្រលប់មកកាន់ធនាគារយើងវិញដោយអ្នកទទួលផល ទោះដោយមធ្យោបាយណាមួយក៏ដោយ ។

២.៤.៣. លោកអ្នកយល់ព្រមថា៖

ក. នៅពេលដែលឯកសារដែលត្រូវបានតម្រូវ ក្រោមលិខិតឥណទាននាំចូលបានមកដល់ លោកអ្នកត្រូវទៅទទួលយកឯកសារទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់មួយ ដូចដែលធនាគារយើងបានជូនដំណឹងទៅកាន់លោកអ្នក និងត្រូវយកឯកសារទាំងនោះ ទៅដូរយកលិខិតធានាលើការដឹកទំនិញច្បាប់ដើមពីក្រុមហ៊ុនដឹកជញ្ជូន ឬអ្នកដឹកទំនិញឯទៀត ព្រមទាំងត្រូវប្រគល់ច្បាប់ដើមនៃលិខិតធានាលើការដឹកទំនិញនោះ ជូនធនាគារយើងឱ្យលឿនបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យធនាគារយើងរួចផុតពីការទទួលខុសត្រូវនានា ដែលយើងមាននៅក្រោមលិខិតធានាលើការដឹកទំនិញនោះ។

ខ. លោកអ្នកនឹងទូទាត់សងប្រាក់ ឬធ្វើស្វ័ការទទួលយកឯកសារដែលត្រូវបានតម្រូវក្រោមលិខិតឥណទាននាំចូល នៅពេលដែលឯកសារនោះបានមកដល់ ទោះបីឯកសារនោះមានភាពស៊ីសង្វាក់ ឬមិនស៊ីសង្វាក់គ្នាក៏ដោយ។

២.៤.៤. តាមការស្នើសុំរបស់ធនាគារយើង លោកអ្នកយល់ព្រមដាក់ទ្រព្យធានា ដែលមានតម្លៃស្មើនឹងកាតព្វកិច្ចរបស់ធនាគារយើង ដែលមាននៅក្រោមលិខិតធានាលើការដឹកទំនិញ ឬ ទឹកប្រាក់ដែលជាសំណងការខូចខាតដែលត្រូវបានផ្តល់ជូនដោយធនាគារយើង សម្រាប់ជាប្រយោជន៍របស់ធនាគារយើង រហូតដល់ពេលដែលលិខិតធានាលើការដឹកទំនិញត្រូវបានប្រគល់ត្រលប់ជូនធនាគារយើងវិញ ដើម្បីលុបចោលនូវកាតព្វកិច្ចធានារបស់ធនាគារយើង និងដែលធ្វើឱ្យធនាគារយើងរួចផុតពីការទទួលខុសត្រូវរបស់ខ្លួន នៅក្រោមលិខិតធានាលើការដឹកទំនិញនេះ។

២.៤.៥. នៅក្នុងគ្រប់ករណីទាំងអស់ និងទៅតាមការទាមទាររបស់ធនាគារយើង លោកអ្នកយល់ព្រមសងសំណងជូនធនាគារយើង ប្រឆាំងនឹងការទូទាត់ណាមួយ ឬទាំងអស់ ដែលធនាគារយើងបានទូទាត់ នៅក្រោមលិខិតធានាលើការដឹកទំនិញ និងរាល់ការទាមទារប្រាក់ នីតិវិធីច្បាប់ បណ្តឹង សកម្មភាព ការទទួលខុសត្រូវ ការខូចខាត និងសោហ៊ុយចំណាយទាំងអស់ (រាប់បញ្ចូលទាំងចំណាយផ្លូវច្បាប់) ដែលធនាគារយើង អាចត្រូវចំណាយ ឬបានចំណាយ ទាក់ទងនឹងលិខិតធានាលើការដឹកទំនិញ។

## ២.៥. លិខិតឥណទានប្រចាំការ

២.៥.១. លិខិតឥណទានប្រចាំការត្រូវតែគោរពតាមវិធាន ISP 98 ឬវិធានរួម UCP 600 ឬវិធានរួម URDG 758 ទោះជាត្រូវបានចេញជូនដោយធនាគារយើង ឬត្រូវបានផ្តល់ការប្រឹក្សាដោយធនាគារយើង ក្នុងនាមជាធនាគារប្រឹក្សាក៏ដោយ។

២.៥.២. លិខិតឥណទានប្រចាំការនីមួយៗ ដែលត្រូវបានចេញជូនដោយធនាគារយើង គឺជាលិខិតដែលមិនអាចដកហូតវិញបាន និងជាប្រតិបត្តិការដាច់ដោយឡែកពី កិច្ចសន្យាចំបង និងការរៀបចំ ឬការព្រមព្រៀង ដែលលោកអ្នកមានជាមួយភាគីឯទៀត។ លិខិតនេះ នឹងចងភ្ជាប់កាតព្វកិច្ចធនាគារយើងដោយមិនពាក់ព័ន្ធនឹងអ្វីដែលអាចកើតឡើងឬចោទឡើង នៅក្នុងកិច្ចសន្យា ឬទំនាក់ទំនងផ្សេងទៀត។ ដូច្នេះ លោកអ្នកយល់ព្រមថា នៅក្នុងករណីដែលមានការទាមទារឱ្យទូទាត់ទឹកប្រាក់ណាមួយ នៅក្រោមលិខិតឥណទានប្រចាំការ ការទាមទារនោះមានលក្ខណៈគ្រប់គ្រាន់ក្នុងការអនុញ្ញាតឱ្យធនាគារយើងអាចធ្វើការទូទាត់ប្រាក់ក្នុងទំហំទឹកប្រាក់អតិបរមា ដូចមានកំណត់នៅក្នុងលិខិតឥណទានប្រចាំការ ដោយមិនចាំបាច់ធ្វើការសាកសួរបន្ថែម ឬមានការយល់ព្រមបន្ថែមពីលោកអ្នកឡើយ។ ដើម្បីចៀសវាងរាល់មន្ទិលសង្ស័យទាំងអស់ ធនាគារយើងនឹងធ្វើការទូទាត់ប្រាក់ ឬធ្វើស្វ័ការទទួលយករូបិយាណត្តិណាមួយ ឬការទាមទារដែលមាននៅក្រោមលិខិតឥណទានប្រចាំការ ទោះបីជាមានការជូនដំណឹងណាមួយពីលោកអ្នក ស្តីពីការហាមឃាត់ធនាគារយើងមិនឱ្យអនុវត្តសិទ្ធិ ឬធ្វើសកម្មភាពណាមួយដូចបានកំណត់និង/ឬអនុញ្ញាតខាងលើក៏ដោយ។

២.៥.៣. ធនាគារយើង អាចត្រួតពិនិត្យលើការទាមទារឱ្យទូទាត់ប្រាក់ណាមួយ ដែលត្រូវបានផ្ញើមកកាន់ធនាគារយើង ក្រោមលិខិតឥណទានប្រចាំការ។ ប្រសិនបើធនាគារយើងជឿជាក់ថា ការទាមទារឱ្យទូទាត់ទឹកប្រាក់នោះ ឬរូបិយាណត្តិ ឬឯកសារឯទៀតដែលត្រូវបានបង្ហាញនៅក្រោមលិខិតឥណទានប្រចាំការ មិនអនុលោមតាមលក្ខខណ្ឌដែលមានចែងនៅក្នុងលិខិតឥណទានប្រចាំការ៖

ក. ធនាគារយើងអាចបដិសេធការទាមទារឱ្យទូទាត់ប្រាក់ ដោយជូនដំណឹងទៅកាន់ភាគីដែលបានធ្វើការទាមទារឱ្យទូទាត់ប្រាក់ ឬបានប្រគល់រូបិយាណត្តិ ឬឯកសារទាំងនោះ មកកាន់ធនាគារយើង និង

ខ. ធនាគារយើងមិនមានកាតព្វកិច្ច ជូនដំណឹងទៅកាន់លោកអ្នកអំពីការសម្រេច ឬការបដិសេធរបស់ធនាគារយើង ឬស្នើសុំការបោះបង់របស់លោកអ្នក ទាក់ទងនឹងការទាមទារឱ្យទូទាត់ប្រាក់ មុនពេលដែលធនាគារយើងសម្រេចឬបដិសេធការទាមទារនោះឡើយ។

២.៥.៤. ប្រការ ២.២.២.ឆ ត្រូវអនុវត្តដូចគ្នាចំពោះ លិខិតឥណទានប្រចាំការ។

២.៥.៥. ធនាគារយើងអាចយល់ព្រមធ្វើជាធនាគារប្រឹក្សាលើលិខិតឥណទានប្រចាំការមួយ ដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌខាងក្រោម៖

ក. ធនាគារយើងអាចយល់ព្រមប្រឹក្សា ឬជូនដំណឹងទៅកាន់លោកអ្នក ប្រសិនបើលិខិតឥណទានប្រចាំការណាមួយ ឬវិសោធនកម្មនៃលិខិតនោះ (ទៅតាមករណីជាក់ស្តែង) មានយថាភូតភាពជាក់ស្តែង ទៅតាមការពេញចិត្តរបស់ធនាគារយើង។

ខ. ធនាគារយើង អាចប្រឹក្សាលិខិតឥណទានប្រចាំការណាមួយ ដែលធនាគារយើងបានទទួល ដោយមិនផ្តល់ការអះអាងឬការសន្យាបន្ថែមណាមួយ ទោះក្រោមទម្រង់ណាក៏ដោយ ទៅកាន់លោកអ្នកដែលជាអ្នកទទួលផលឡើយ។

គ. បន្ទាប់ពីទទួលបានការស្នើសុំ ដោយភ្ជាប់ជាមួយការទាមទារឱ្យទូទាត់ប្រាក់ ដែលមានលក្ខណៈត្រឹមត្រូវពីលោកអ្នក ធនាគារយើងនឹងដំណើរការការទាមទារឱ្យទូទាត់ប្រាក់នោះ ទៅកាន់ធនាគារចេញលិខិត នៅក្នុងនាមរបស់លោកអ្នក ដើម្បីទាមទារការទូទាត់ទឹកប្រាក់នៅក្រោមលិខិតឥណទានប្រចាំការនោះ។ បន្ទាប់ពីទទួលបានការទូទាត់ទឹកប្រាក់ពីធនាគារចេញលិខិត ធនាគារយើងនឹងបញ្ចូលទឹកប្រាក់ទាំងនោះ ដោយដកចេញនូវកម្រៃសេវា និងសោហ៊ុយចំណាយ ដែលធនាគារយើងអាចទទួលរង ឬបានចំណាយ ពាក់ព័ន្ធនឹងការដំណើរការការទាមទារការទូទាត់ប្រាក់នោះ ទៅក្នុងគណនីដែលត្រូវបានកំណត់របស់លោកអ្នក។ ប៉ុន្តែ ប្រសិនបើធនាគារចេញលិខិត បដិសេធការទាមទារឱ្យទូទាត់ប្រាក់ ធនាគារយើងមិនមានកាតព្វកិច្ចផ្ទេរប្រាក់ណាមួយជូនលោកអ្នកឡើយ។

## ២.៦. សេវាប្រមូលឯកសារ

២.៦.១. សេចក្តីណែនាំឱ្យប្រមូលឯកសារនីមួយៗ រាប់បញ្ចូលទាំង សេចក្តីណែនាំបន្តបន្ទាប់ដែលពាក់ព័ន្ធ ដែលត្រូវបានប្រតិបត្តិដោយធនាគារយើង ត្រូវគោរពតាមវិធានរួម URC 522 ហើយធនាគារយើងអាចយល់ព្រមដំណើរការសេវាប្រមូលឯកសារ ទៅតាមសេចក្តីណែនាំឱ្យប្រមូលឯកសាររបស់លោកអ្នក ជាមួយធនាគារប្រមូលឯកសារ (“**សេវាប្រមូលឯកសារនាំចេញ**”) ដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌខាងក្រោម៖

ក. លោកអ្នក ត្រូវផ្តល់ជូនធនាគារយើង នូវសេចក្តីណែនាំឱ្យប្រមូលឯកសារ ដែលត្រឹមត្រូវនិងពេញលេញ រួមជាមួយនឹងឯកសារទាំងអស់ដែលត្រូវបានតម្រូវឱ្យផ្ញើចេញ ដើម្បីធ្វើការប្រមូលឯកសារ អនុលោមតាមសេចក្តីណែនាំឱ្យប្រមូលឯកសារ។ ធនាគារយើង មិនមានកាតព្វកិច្ចត្រួតពិនិត្យលើឯកសារទាំងនោះ មុនពេលផ្ញើទៅកាន់ធនាគារប្រមូលឯកសារឡើយ។ លោកអ្នកយល់ព្រមថា គ្មានសកម្មភាព ឬអកម្មភាពណាមួយរបស់ធនាគារយើង ទាក់ទងនឹងឯកសារដែលធនាគារយើងបានទទួលពីលោកអ្នក ត្រូវប៉ះពាល់ដល់សិទ្ធិប្តឹងទាមទារសំណងការខូចខាតដែលធនាគារយើងមានប្រឆាំងនឹងលោកអ្នកឡើយ បន្ទាប់ពីការទូទាត់នៅក្រោមសេវាប្រមូលឯកសារត្រូវបានបដិសេធ ឬស្វីការទទួលយកឯកសារនៅក្រោមសេវាប្រមូលឯកសារត្រូវបានទទួលយក ឬមិនបានធ្វើការបង្ហាញឯកសារ។

ខ. លោកអ្នក យល់ព្រមបង់ជូនធនាគារយើង នូវរាល់កម្រៃសេវា និងសោហ៊ុយចំណាយនានា ដែលធនាគារយើងបានចំណាយ ឬនឹងត្រូវចំណាយ ទាក់ទងនឹងសេវាប្រមូលឯកសារ និងបញ្ញត្តិនិងលក្ខខណ្ឌនេះ ទោះបីជាការប្រមូលឯកសារមិនត្រូវបានទូទាត់ក៏ដោយ ហើយលោកអ្នកយល់ព្រមអនុញ្ញាតឱ្យ ធនាគារយើងធ្វើការកាត់ប្រាក់ដោយស្វ័យប្រវត្តិនិងដោយផ្ទាល់ ចេញពីគណនីដែលត្រូវបានកំណត់របស់លោកអ្នក ឬគណនីណាមួយ ដោយមិនចាំបាច់ធ្វើការជូនដំណឹង ឬទទួលបានការយល់ព្រមបន្ថែមពីលោកអ្នកឡើយ។ ដើម្បីចៀសវាងរាល់

មន្ទិលសង្ស័យ លោកអ្នកយល់ព្រមថា ធនាគារយើងនឹងទូទាត់ជូនលោកអ្នក តែចំនួនទឹកប្រាក់ដែលធនាគារយើង បានទទួលពីធនាគារប្រមូលឯកសារតែប៉ុណ្ណោះ។

គ. ផ្អែកលើឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារយើងអាចផ្ញើឯកសារនៃការប្រមូលឯកសារ និងសេចក្តីណែនាំប្រមូលឯកសារ ដើម្បីទទួលបានការទូទាត់ប្រាក់ តាមរយៈធនាគារទំនាក់ទំនងណាមួយ ហើយបញ្ញត្តិនិងលក្ខខណ្ឌរបស់ធនាគារទំនាក់ទំនងនោះ ត្រូវមានអានុភាពអនុវត្ត។

ឃ. ធនាគារយើងមិនទទួលខុសត្រូវលើរាល់ការខូចខាតទាំងឡាយ ដែលលោកអ្នកឬបុគ្គលណាមួយ បានទទួលរង កើតចេញពីការទទួលបានការទូទាត់ប្រាក់យឺតយ៉ាវពីធនាគារប្រមូលឯកសារឡើយ។

២.៦.២. ផ្អែកលើឆន្ទានុសិទ្ធិដាច់ខាតរបស់ខ្លួន ធនាគារយើងអាចយល់ព្រមដំណើរការសេវាប្រមូលឯកសារនាំចូល ឬសេចក្តីណែនាំបន្តបន្ទាប់ណាមួយ ដែលត្រូវបានបង្ហាញមកកាន់ធនាគារយើង ដោយគោរពតាមបញ្ញត្តិនិងលក្ខខណ្ឌខាងក្រោម៖

ក. ធនាគារយើងនឹងធ្វើសកម្មភាពដោយផ្អែកលើសេចក្តីណែនាំឱ្យប្រមូលឯកសារ ដែលធនាគារយើងបានទទួលប៉ុណ្ណោះ។ ធនាគារយើង នឹងសម្រេចថាឯកសារដែលបានទទួលត្រូវបានមើលឃើញថា ស្របជាមួយឯកសារដែលមានបញ្ជាក់នៅក្នុងសេចក្តីណែនាំឱ្យប្រមូលឯកសារ ហើយធនាគារយើង នឹងផ្តល់ការប្រឹក្សាជូនភាគីដែលធនាគារយើងបានទទួលសេចក្តីណែនាំឱ្យប្រមូលឯកសារ លើឯកសារដែលបាត់បង់ ឬត្រូវបានរកឃើញថាមិនមាននៅក្នុងបញ្ជីឯកសារ នៃសេចក្តីណែនាំឱ្យប្រមូលឯកសារ។ ដើម្បីចៀសវាងរាល់មន្ទិលសង្ស័យ ធនាគារយើងមិនមានកាតព្វកិច្ចត្រួតពិនិត្យឯកសារណាមួយឡើយ ហើយក្នុងករណីនេះ ធនាគារយើងនឹង៖

i. បង្ហាញឯកសារទៅកាន់លោកអ្នក ក្នុងទម្រង់ដែលធនាគារយើងបានទទួល ដោយមិនមានការត្រួតពិនិត្យណាមួយឡើយ និង

ii. ធនាគារយើងអាចកាន់កាប់ឯកសារទុក រហូតដល់ពេលដែលធនាគារយើងបានទទួលការធ្វើស៊ីការទទួលយកឯកសារ ឬការទូទាត់ពីលោកអ្នក (ទៅតាមករណីជាក់ស្តែងនីមួយៗ) និង/ឬ

iii. ជូនដំណឹងលោកអ្នកអំពី លក្ខខណ្ឌបន្ថែមណាមួយ នៅក្នុងឯកសារទំនាក់ទំនងដែលមានភ្ជាប់ជាមួយនឹងសេវាប្រមូលឯកសារនាំចូល។

ខ. ធនាគារយើងនឹងធ្វើការទូទាត់ប្រាក់ តែនៅពេលដែលធនាគារយើង បានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីលោកអ្នក ដែលអនុញ្ញាតឱ្យធនាគារយើងធ្វើការកាត់ប្រាក់ចេញពីគណនីរបស់លោកអ្នក ដែលមាននៅជាមួយធនាគារយើង ហើយធនាគារយើងនឹងប្រគល់ឯកសារជូនលោកអ្នក បន្ទាប់ពីធនាគារយើងបានទទួលលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរនោះ ដើម្បីកាត់ទឹកប្រាក់ចេញពីគណនីរបស់លោកអ្នក ដែលមានសមតុល្យគ្រប់គ្រាន់ក្នុងការទូទាត់ ឬបន្ទាប់ពីយើងបានទទួលស៊ីការរបស់លោកអ្នក ដែលយល់ព្រមទូទាត់នៅតណប្រតិទាន ឬបន្ទាប់ពីរូបិយាណត្តិត្រូវបានចុះហត្ថលេខានិងធ្វើស៊ីការទទួលយកដោយលោកអ្នក (ទៅតាមករណីជាក់ស្តែង)។

គ. លោកអ្នកយល់ព្រមថា ធនាគារយើងមិនទទួលខុសត្រូវលើរាល់ការបាត់បង់ ឬខូចខាត ដែលបានទទួលរងពីការដែលធនាគារយើងអនុវត្តតាមសេចក្តីណែនាំរបស់ធនាគារផ្ញើ ហើយសេចក្តីណែនាំរបស់លោកអ្នកដែលមិនស៊ីសង្វាក់គ្នា នឹងត្រូវបានបញ្ជូនទៅកាន់ធនាគារផ្ញើ។

២.៦.៣. ភាគីដែលរៀបចំសេចក្តីណែនាំឱ្យប្រមូលឯកសារ ត្រូវទទួលខុសត្រូវក្នុងការធានាឱ្យបានថា លក្ខខណ្ឌក្នុងការប្រគល់ឯកសារ ត្រូវបានចែងច្បាស់លាស់ដោយគ្មានភាពស្រពិចស្រពិល។ សេចក្តីណែនាំឱ្យប្រមូលឯកសារគួរមានព័ត៌មានដូចខាងក្រោម ទៅតាមភាពសមស្រប៖

ក. ព័ត៌មានលម្អិតនៃធនាគារ ដែលបានបញ្ជូនសេចក្តីណែនាំឱ្យប្រមូលឯកសារ រាប់បញ្ចូលទាំង ឈ្មោះពេញ អាសយដ្ឋានប្រៃសណីយ៍ និង ស្វីហ្វ (postal and SWIFT address) តេឡិច (telex) លេខទូរស័ព្ទ លេខទូរសារ និងការយោង។

ខ. ព័ត៌មានលម្អិតរបស់ បុគ្គលដែលបានផ្តល់សេចក្តីណែនាំឱ្យប្រមូលឯកសារទៅកាន់ធនាគារផ្ញើ រួមបញ្ចូលទាំងឈ្មោះពេញ អាសដ្ឋានប្រៃសណីយ៍ និងប្រសិនបើអាចធ្វើបាន តេឡិច (telex) លេខទូរស័ព្ទ លេខទូរសារ។

គ. ព័ត៌មានលម្អិតរបស់អ្នកបង់ប្រាក់ រាប់បញ្ចូលទាំង ឈ្មោះពេញ អាសយដ្ឋានប្រៃសណីយ៍ និង ស្វីហ្វ (postal and SWIFT address) និងប្រសិនបើអាចធ្វើបាន តេឡិច (telex) លេខទូរស័ព្ទ លេខទូរសារ និងការយោង។

ឃ. ព័ត៌មានលម្អិតរបស់ធនាគារបង្ហាញឯកសារ ប្រសិនបើមាន រួមបញ្ចូលទាំង ឈ្មោះពេញ អាសដ្ឋាន ប្រៃសណីយ៍ និងប្រសិនបើអាចធ្វើបាន តេឡិច (telex) លេខទូរស័ព្ទ លេខទូរសារ។

ង. ចំនួនទឹកប្រាក់ និងប្រភេទនៃរូបិយវត្ថុ ដែលត្រូវប្រមូល។

ច. បញ្ជីឯកសារភ្ជាប់ និងការរាប់លេខរៀងនៃឯកសារនីមួយៗ។

ឆ. លក្ខខណ្ឌតម្រូវ ដើម្បីទទួលបានការទូទាត់ ឬការធ្វើស្វីការទទួលយកឯកសារ លក្ខខណ្ឌនៃការប្រគល់ឯកសារ (i) ដើម្បីធ្វើការទូទាត់ ឬការធ្វើស្វីការទទួលយកឯកសារ ឬ (ii) បញ្ញត្តិនិងលក្ខខណ្ឌផ្សេង ទៀត។

ជ. កម្រៃសេវាដែលត្រូវប្រមូល ដោយចង្អុលបង្ហាញថា កម្រៃសេវាទាំងនោះអាចត្រូវបានលើកលែង ឬមិនត្រូវបាន លើកលែង។

ឈ.ការប្រាក់ដែលត្រូវប្រមូល ប្រសិនបើអនុវត្ត ដោយចង្អុលបង្ហាញថា ការប្រាក់ទាំងនោះអាចត្រូវបានលើកលែង ឬមិនត្រូវបានលើកលែង រាប់បញ្ចូលទាំង (i). អត្រានៃការប្រាក់ (ii). អំឡុងពេលនៃការប្រាក់ (iii). មូលដ្ឋាននៃ ការគណនាការប្រាក់ (ឧទាហរណ៍ ៣៦០ថ្ងៃ ឬ ៣៦៥ថ្ងៃ ក្នុងមួយឆ្នាំ) ទៅតាមការដែលអនុវត្តបាន។

ញ. របៀបនៃការទូទាត់ប្រាក់ និងទម្រង់នៃប្រឹក្សាលើការទូទាត់ប្រាក់។

ដ. សេចក្តីណែនាំក្នុងករណី មិនទូទាត់ មិនធ្វើស្វីការទទួលយកឯកសារ និង/ឬ មិនអនុលោមតាមសេចក្តីណែនាំ ផ្សេងទៀត។

២.៦.៤. ធនាគារយើងនឹងធ្វើប្រតិបត្តិការដោយសុចរិត និងដោយយកចិត្តទុកដាក់ក្នុងការផ្តល់សេវាប្រមូលឯកសារ ហើយ ធនាគារយើងមិនមានការទទួលខុសត្រូវណាមួយ ទាក់ទងនឹង ការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវបណ្តាលមក ពីព័ត៌មានមិនពេញលេញឬមិនត្រឹមត្រូវ ដែលមានចែងក្នុងសេចក្តីណែនាំឱ្យប្រមូលឯកសារនោះឡើយ។ លោកអ្នក យល់ព្រមសងសំណងការខូចខាតជូនធនាគារយើងទាក់ទងនឹង ការទាមទារ ការបាត់បង់ ទំនួលខុសត្រូវ សោហ៊ុយចំណាយ ដែលកើតឡើងចេញពី ឬទាក់ទងនឹង សេវាប្រមូលឯកសារណាមួយ ដែលធនាគារយើងបាន ដំណើរការតាមការស្នើសុំរបស់លោកអ្នក។

## ២.៧. ឥណទានហិរញ្ញប្បទានពាណិជ្ជកម្ម

២.៧.១. ផ្អែកលើឆន្ទានុសិទ្ធិតែមួយគត់របស់ខ្លួន ធនាគារយើងអាចយល់ព្រមផ្តល់ជូនលោកអ្នក នូវឥណទានហិរញ្ញប្បទាន ពាណិជ្ជកម្មទៅតាមការស្នើសុំរបស់លោកអ្នក និងដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌនេះ។ លោកអ្នក ត្រូវ ប្រគល់ជូន ធនាគារយើងនូវរាល់ព័ត៌មាននិងឯកសារដែលពាក់ព័ន្ធនានា នៅពេលលោកអ្នកដាក់ពាក្យស្នើសុំឥណទាន ឬនៅកាលបរិច្ឆេទផ្សេងទៀត ទៅតាមការទាមទាររបស់ធនាគារយើង សម្រាប់គោលបំណងនៃការសិក្សាឥណទាន។

២.៧.២. លោកអ្នក ត្រូវចុះហត្ថលេខា/ផ្តិតស្នាមម្រាមដៃលើឯកសារដែលពាក់ព័ន្ធ ដែលត្រូវបានតម្រូវដោយ ធនាគារយើង រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ សំណុំឯកសារហិរញ្ញប្បទាន។ លោកអ្នកយល់ព្រមថា ឥណទានហិរញ្ញប្បទាន ពាណិជ្ជកម្មនីមួយៗ ដែលធនាគារយើងបានផ្តល់ជូនលោកអ្នក ត្រូវគោរពតាមបញ្ញត្តិនិងលក្ខខណ្ឌដែលមានចែង ក្នុងសំណុំឯកសារហិរញ្ញប្បទាន។

២.៨. ធនាគារយើងអាច បន្ថែម កែប្រែ ព្យួរ ឬលុបចោល ការផ្តល់សេវាណាមួយ នៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទាន ពាណិជ្ជកម្ម នៅពេលណាមួយ ដោយជូនដំណឹងទៅកាន់លោកអ្នក តាមរយៈមធ្យោបាយទំនាក់ទំនងដែលមាន រួមទាំង គេហទំព័រផ្លូវការរបស់ធនាគារយើង។

២.៩ លោកអ្នកយល់ព្រមថា បន្ទាប់ពីធនាគារយើងបានទទួលពាក្យស្នើសុំរបស់លោកអ្នក ធនាគារយើងមានសិទ្ធិក្នុងការធ្វើ សកម្មភាពទៅតាមការស្នើសុំ ឬបដិសេធការស្នើសុំ ដោយមិនចាំបាច់មានមូលហេតុ នឹងដោយជូនដំណឹងទៅកាន់លោកអ្នក អំពីការបដិសេធនោះ។

២.១០. យោងតាមការស្នើសុំរបស់លោកអ្នក និងផ្អែកលើឆន្ទានុសិទ្ធិដាច់ខាតរបស់ខ្លួន ធនាគារយើងអាចយល់ព្រម ឬបដិសេធធ្វើ វិសោធនកម្ម ទៅលើផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ ដែលបានផ្តល់ជូនដោយធនាគារយើង

អនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌនេះ ដោយធ្វើការជូនដំណឹងទៅកាន់លោកអ្នក។ នៅពេលមានការស្នើសុំធ្វើវិសោធនកម្ម លើផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ លោកអ្នកយល់ព្រមបង់កម្រៃសេវាបន្ថែម និងសោហ៊ុយចំណាយផ្សេងទៀតជូនធនាគារយើង តាមការកំណត់របស់ធនាគារយើង និងដោយមានការជូនដំណឹងទៅកាន់លោកអ្នក។

២.១១. លោកអ្នក អះអាងបញ្ជាក់ថា លោកអ្នកយល់និងយល់ព្រមយ៉ាងពេញលេញ ក្នុងការទទួលយកនូវរាល់ហានិភ័យទាំងឡាយដែលពាក់ព័ន្ធនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម។ លោកអ្នក ត្រូវទទួលខុសត្រូវទាំងស្រុង ក្នុងការគ្រប់គ្រងហានិភ័យទាំងនោះ ដោយផ្អែកលើការខិតខំផ្ទាល់ខ្លួនរបស់លោកអ្នក។ លោកអ្នក ទទួលស្គាល់និងយល់ព្រមថា ព័ត៌មានឬសេវាហិរញ្ញវត្ថុណាមួយ ដែលធនាគារយើងបានផ្តល់ជូនលោកអ្នក ដើម្បីជួយលោកអ្នកគ្រប់គ្រងហានិភ័យបន្ថែមណាមួយ មិនមែននិងមិនត្រូវចាត់ទុក ជាការប៉ុនប៉ងរបស់ធនាគារយើងក្នុងការធ្វើសកម្មភាពក្នុងទម្រង់ណាមួយក្នុងលក្ខណៈជាការផ្តល់យោបល់ ឬការគ្រប់គ្រងចាត់ចែងជូនលោកអ្នកឡើយ។

២.១២. បន្ទាប់ពីបានទទួលពាក្យស្នើសុំរបស់លោកអ្នក លោកអ្នកយល់ព្រមអនុញ្ញាត ដោយគ្មានលក្ខខណ្ឌនិងដោយមិនអាចដកហូតវិញបានឱ្យធនាគារយើង៖

ក. ចូលទៅកាន់គណនី ដូចមានកំណត់ក្នុងពាក្យស្នើសុំ និងគណនីផ្សេងទៀតរបស់លោកអ្នក ដែលបានបើកនិងរក្សាជាមួយធនាគារយើង

ខ. បង្ហាញព័ត៌មានណាមួយឬទាំងអស់របស់លោកអ្នក ដែលមាននៅក្នុងការកាន់កាប់របស់ធនាគារយើង រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ ទិន្នន័យផ្ទាល់ខ្លួន ទៅកាន់អ្នកផ្គត់ផ្គង់សេវា ដៃគូអាជីវកម្ម ឬតតិយភាគីណាមួយ ទៅតាមការតម្រូវរបស់ពួកគេ ដើម្បីជួយឱ្យធនាគារយើងអាចផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មដែលបានស្នើសុំជូនលោកអ្នក

គ. កត់ត្រាទុកព័ត៌មានលម្អិតទាំងអស់ដែលទាក់ទងនឹងប្រតិបត្តិការ នៅក្នុងកំណត់ត្រារបស់ធនាគារយើង ហើយលោកអ្នកយល់ព្រមថា រាល់កំណត់ត្រាទាំងអស់ដែលត្រូវបានទាញចេញពីប្រព័ន្ធរក្សាទុកព័ត៌មានរបស់ធនាគារយើង ដែលទាក់ទងការផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម រាប់បញ្ចូលទាំងពេលវេលាដែលប្រតិបត្តិការត្រូវបានកត់ត្រា ហើយកំណត់ត្រានេះត្រូវបានចាត់ទុកថាជាភស្តុតាងចុងក្រោយ ត្រឹមត្រូវ និងពិតប្រាកដ នៃប្រតិបត្តិការ និង

ឃ. ធ្វើរាល់សកម្មភាពចាំបាច់នានា ដើម្បីធានាការផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ជូនលោកអ្នក។

២.១៣. ធនាគារយើង អាចផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម តាមរយៈធនាគារទំនាក់ទំនង ហើយផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មនោះ ត្រូវបានចាត់ទុកថាបានផ្តល់ជូនលោកអ្នកនៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ។ លោកអ្នក យល់និងព្រមព្រៀងថា នៅក្នុងកាលៈទេសៈណាក៏ដោយ ធនាគារយើងមិនត្រូវទទួលខុសត្រូវលើរាល់ការខូចខាតទាំងឡាយដែលលោកអ្នកបានទទួលរង បណ្តាលមកពីការក្ស័យធន ឬបរាជ័យណាមួយរបស់ធនាគារទំនាក់ទំនង ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មឡើយ។

២.១៤. លោកអ្នកយល់ព្រមថា ធនាគារយើងមានសិទ្ធិក្នុងការផ្តល់ជូន នូវផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ ដោយមិនចាំបាច់សាកសួរពី៖

ក. យថាភូតភាពនៃការស្នើសុំ ឬពាក្យស្នើសុំឱ្យផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ ដែលត្រូវបានចុះហត្ថលេខា ដោយអ្នកតំណាងដែលទទួលបានការអនុញ្ញាត ឬបានផ្ញើតាមទូរសារឬអ៊ីម៉ែលឬតាមមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀត ឬ

ខ. សិទ្ធិអំណាចរបស់អ្នកតំណាងដែលទទួលបានការអនុញ្ញាត ត្រូវបានឬមិនត្រូវបានដកហូត ឬកម្រិត លើកលែងតែធនាគារយើង បានទទួលនិងធ្វើសកម្មភាពដោយផ្អែកលើ សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលមានខ្លឹមសារផ្ទុយ និងដែលត្រូវបានចុះហត្ថលេខាដោយលោកអ្នក ឬក្នុងនាមរបស់លោកអ្នក។

២.១៥. លោកអ្នកយល់ព្រមថា ទំនាក់ទំនងណាមួយទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មនីមួយៗ អាចត្រូវបានធ្វើតាមរយៈ លិខិត ទូរសារ ស្វីហ្វ(SWIFT) អ៊ីម៉ែល ឬមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀត ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀត តាមឆន្ទានុសិទ្ធិរបស់ធនាគារយើង។

## ៣. កម្រៃសេវា សោហ៊ុយចំណាយផ្សេងៗ និងការទូទាត់ប្រាក់នៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម

### ៣.១. កម្រៃសេវា

៣.១.១. លោកអ្នក យល់ព្រមបង់កម្រៃសេវាជូនធនាគារយើង ទៅតាមការជូនដំណឹងរបស់ធនាគារយើង សម្រាប់ផលិតផល និងសេវាហិរញ្ញប្បទានពាណិជ្ជកម្មដែលបានផ្តល់ជូន និងដែលមាននៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ តទៅនេះហៅថា "**កម្រៃសេវា**"។ លោកអ្នកយល់ព្រមអនុញ្ញាតឱ្យធនាគារយើង កែប្រែ ឬធ្វើវិសោធនកម្មលើ កម្រៃសេវា ដោយធ្វើការជូនដំណឹងទៅកាន់លោកអ្នក តាមរយៈមធ្យោបាយទំនាក់ទំនងដែលមានរបស់ធនាគារយើង រួមទាំង គេហទំព័រផ្លូវការរបស់ធនាគារយើង។

៣.១.២. លោកអ្នកយល់ព្រមធ្វើការទូទាត់ ឬសងត្រឡប់មកកាន់ធនាគារយើង ទៅតាមការទាមទាររបស់ធនាគារយើង នូវរាល់ការចំណាយ សោហ៊ុយចំណាយផ្សេងៗ ដែលបានកើតឡើង ទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ដែលធនាគារយើងបានផ្តល់ជូន វិសោធនកម្មជាបន្តបន្ទាប់នៃផលិផលនិងសេវាទាំងនោះ ការចរចារ ការរៀបចំ ការពន្យារ ការកែប្រែ (ទៅតាមករណីជាក់ស្តែង) រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ ចំណាយពន្ធដារពាក់ព័ន្ធដែលអនុវត្ត កម្រៃសេវាចុះបញ្ជី ការចំណាយជាយថាហេតុណាមួយ កម្រៃសេវាផ្លូវច្បាប់ កម្រៃសេវាវាយតម្លៃ បុព្វលាភធានារ៉ាប់រង ការចំណាយផ្សេងៗទៀតដែលទាក់ទងនឹងប្រាតិភោគ និងការអនុវត្តបញ្ញត្តិ និងលក្ខខណ្ឌនេះ ("**សោហ៊ុយចំណាយ**")។ នៅក្នុងករណីដែល ការចំណាយក្នុងការរក្សាឬដំណើរការ ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មបានកើនឡើង ដើម្បីឱ្យធនាគារយើងគោរពតាមច្បាប់ឬបញ្ញត្តិណាមួយ ("**ការចំណាយដែលកើន**") លោកអ្នកយល់ព្រមដោយមិនអាចដកហូតវិញបានក្នុងការបង់ជូនធនាគារយើង នូវការចំណាយដែលកើននោះ ទៅតាមការទាមទាររបស់ធនាគារយើង។

### ៣.២. ការទូទាត់ប្រាក់ នៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម

៣.២.១. លោកអ្នក យល់ព្រមដោយមិនអាចដកហូតវិញថា ការបង្ហាញឯកសារ ឬការទាមទារឱ្យទូទាត់ប្រាក់ ដែលធនាគារយើងឬធនាគារទំនាក់ទំនងរបស់ធនាគារយើង បានសម្រេចថាមានភាពត្រឹមត្រូវ ត្រូវចងភ្ជាប់កាតព្វកិច្ចចំពោះលោកអ្នក និងត្រូវមានសុពលភាព ព្រមទាំងជាភស្តុតាងចុងក្រោយដែលបង្ហាញថា ធនាគារយើង ឬធនាគារទំនាក់ទំនងរបស់ធនាគារយើង មានទំនួលខុសត្រូវក្នុងការទូទាត់ប្រាក់ នៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មដែលធនាគារយើងបានផ្តល់ជូន។

៣.២.២. លោកអ្នក យល់ព្រមអនុញ្ញាតដោយគ្មានលក្ខខណ្ឌនិងដោយមិនអាចដកហូតវិញបាន ឱ្យធនាគារយើងធ្វើការបដិសេធការទាមទារឱ្យទូទាត់ប្រាក់ដែលមានលក្ខណៈមិនត្រឹមត្រូវ ឬធ្វើការទូទាត់ប្រាក់ណាមួយជូនទៅអ្នកទទួលផលបន្ទាប់ពីធនាគារយើងបានទទួលការបង្ហាញឯកសារ ឬការទាមទារឱ្យទូទាត់ប្រាក់ដែលមានលក្ខណៈត្រឹមត្រូវ នៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ នៅក្នុងរូបិយវត្ថុ និងដោយអនុលោមតាមលក្ខខណ្ឌដែលមានចែងនៅក្នុងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មជាក់ស្តែងនីមួយៗ ដោយមិនចាំបាច់ធ្វើការស៊ើបអង្កេតណាមួយ ឬធ្វើការយោងទៅលើសិទ្ធិអំណាចណាមួយពីលោកអ្នក ឬទាមទារភស្តុតាងបញ្ជាក់ថាចំនួនទឹកប្រាក់ណាមួយ បានឬកំពុងដល់កាលកំណត់ទូទាត់ពីលោកអ្នកនៅក្រោមកិច្ចសន្យាចំបង និងទោះបីជាលោកអ្នកកំពុងមានវិវាទទាក់ទងនឹងសុពលភាពនៃ ការបង្ហាញឯកសារ ឬការទាមទារឱ្យទូទាត់ប្រាក់ណាមួយ ឬកាលបរិច្ឆេទផុតសុពលភាព នៃផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មនោះ។ លោកអ្នកយល់ព្រមបន្ថែមទៀតថាធនាគារយើងមិនត្រូវទទួលខុសត្រូវលើការបាត់បង់ ឬការខូចខាតណាមួយ ដែលកើតចេញពីការទូទាត់ប្រាក់ដែលធនាគារយើងបានធ្វើការទូទាត់ ឬបដិសេធទូទាត់ ទោះបីជាលោកអ្នកបានផ្តល់ការណែនាំដែលមានខ្លឹមសារផ្ទុយមកកាន់ធនាគារយើងក៏ដោយ។

៣.២.៣. លោកអ្នក ធានាថាលោកអ្នកមានសមតុល្យគ្រប់គ្រាន់ នៅក្នុងគណនីដែលត្រូវបានកំណត់ ដើម្បីធ្វើការទូទាត់ប្រាក់ជូនទៅអ្នកទទួលផល ផ្អែកលើការបង្ហាញឯកសារឬការទាមទារឱ្យទូទាត់ប្រាក់ដែលមានលក្ខណៈត្រឹមត្រូវ និងដើម្បីទូទាត់ជូនធនាគារយើងនូវរាល់ កម្រៃសេវា សោហ៊ុយចំណាយ និងចំណាយដែលកើន។ លោកអ្នក អនុញ្ញាត

ដោយគ្មានលក្ខខណ្ឌនិងដោយមិនអាចដកហូតវិញបានឱ្យធនាគារយើង កាត់ប្រាក់ដោយស្វ័យប្រវត្តិ ចេញពីគណនីដែលត្រូវបានកំណត់ ដើម្បីធ្វើការទូទាត់ប្រាក់ជូនទៅអ្នកទទួលផល និងបង់កម្រៃសេវា សោហ៊ុយចំណាយ និងចំណាយដែលកើនជូនធនាគារយើង ដោយមិនចាំបាច់ជូនដំណឹង ឬទទួលបានការយល់ព្រមបន្ថែមពីលោកអ្នក ឬដោយមិនចាំបាច់តម្រូវឱ្យធនាគារយើងទទួលបានលិខិតជូនដំណឹងស្តីពីការបញ្ចេញឥណទាន ក្នុងករណីធនាគារយើងយល់ព្រមផ្តល់ឥណទានណាមួយជូនលោកអ្នក ដើម្បីប្រើប្រាស់សម្រាប់ធ្វើការទូទាត់ប្រាក់ទៅឱ្យអ្នកទទួលផល ឬអ្នកទទួលប្រាក់ណាមួយ និងសម្រាប់ទូទាត់រាល់កម្រៃសេវា សោហ៊ុយចំណាយ និងចំណាយដែលកើន។ នៅក្នុងករណីដែលមិនមានសមតុល្យគ្រប់គ្រាន់នៅក្នុងគណនីដែលត្រូវបានកំណត់ ដើម្បីធ្វើការទូទាត់ប្រាក់ដែលដល់កំណត់ទូទាត់ លោកអ្នកយល់ព្រមអនុញ្ញាតដោយគ្មានលក្ខខណ្ឌនិងដោយមិនអាចដកហូតវិញបាន ឱ្យធនាគារយើងធ្វើការកាត់ប្រាក់ដោយស្វ័យប្រវត្តិ ចេញពីគណនីណាមួយ ឬទាំងអស់របស់លោកអ្នក ដែលមានសមតុល្យ ឬ ធនាគារយើងអាចបំបែកគណនីបញ្ញើមានកាលកំណត់ ឬបម្លែងទឹកប្រាក់ដែលមានក្នុងរូបិយវត្ថុមួយទៅរូបិយវត្ថុមួយទៀត (ក្នុងអត្រាប្តូរប្រាក់ដែលអនុវត្ត) ដោយមិនចាំបាច់ជូនដំណឹង ឬទទួលបានការយល់ព្រមបន្ថែមពីលោកអ្នកឡើយ ឬ ធនាគារយើងអាចលុបចោលឬបដិសេធអនុវត្តប្រតិបត្តិការណាមួយដែលលោកអ្នកបានស្នើសុំ នៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម។ ក្នុងករណីនេះ លោកអ្នក យល់ព្រមថាធនាគារយើងមិនត្រូវទទួលខុសត្រូវលើការបាត់បង់ ឬការខូចខាតណាមួយ ដែលកើតចេញពីការលុបចោលឬការបដិសេធនោះឡើយ។

៣.២.៤. នៅក្នុងករណីដែលធនាគារយើងបានទទួលការទាមទារឱ្យទូទាត់ប្រាក់ពីអ្នកទទួលផល លោកអ្នកត្រូវបង់ប្រាក់ជូនធនាគារយើងភ្លាមៗ ទៅតាមការទាមទាររបស់ធនាគារយើង។ ផ្ទុយទៅវិញ ប្រសិនបើលោកអ្នកខកខានក្នុងការបង់ប្រាក់ជូនធនាគារយើងតាមការទាមទាររបស់ធនាគារយើង ទោះដោយប្រការណាមួយក៏ដោយ ហើយធនាគារយើងត្រូវធ្វើការទូទាត់ប្រាក់ដែលដល់កំណត់ទូទាត់ទៅកាន់អ្នកទទួលផល នៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម លោកអ្នកត្រូវសងត្រឡប់មកកាន់ធនាគារយើងវិញភ្លាមៗ តាមការទាមទារធនាគារយើងនូវ (១). ទឹកប្រាក់ទាំងអស់ដែលធនាគារយើងបានបង់ជូនអ្នកទទួលផល (២). ការប្រាក់ក្នុងអត្រារហូតដល់១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ ឬក្នុងអត្រាអតិបរមាដូចបានអនុញ្ញាតដោយបញ្ញត្តិច្បាប់ជាធរមាន ដោយគណនាលើទឹកប្រាក់ទាំងអស់ដែលលោកអ្នកជំពាក់ធនាគារយើង គិតចាប់ពីកាលបរិច្ឆេទដែលធនាគារយើងបានទូទាត់ប្រាក់ទៅឱ្យអ្នកទទួលផល ឬអ្នកទទួលប្រាក់ (៣). ការប្រាក់ក្នុងករណីបំពានលក្ខខណ្ឌ ក្នុងអត្រា២៤%(ម្ភៃបួនភាគរយ)ក្នុងមួយឆ្នាំ ឬក្នុងអត្រាអតិបរមាដូចបានអនុញ្ញាតដោយបញ្ញត្តិច្បាប់ជាធរមាន ដោយគណនាលើទឹកប្រាក់សរុបដែលលោកអ្នកជំពាក់ធនាគារយើង និង (៤). ចំណាយសេវាកម្មច្បាប់ កម្រៃសេវា សោហ៊ុយចំណាយ និងការខូចខាតដែលធនាគារយើងបានទទួលរង រួមជាមួយថ្លៃចំណាយនានាក្នុងនីតិវិធីតុលាការ នៅក្នុងប្រទេសកម្ពុជា ឬនៅបរទេសណាមួយ ដែលទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម។

៣.២.៥. លោកអ្នក យល់ព្រមថា រាល់ចំនួនទឹកប្រាក់ដែលដល់កំណត់ទូទាត់ លោកអ្នកត្រូវទូទាត់ជូនធនាគារយើងឱ្យបានគ្រប់ចំនួន និងដោយមិនមានជាប់បន្ទុកបង់ពន្ធ។ ក្នុងករណីដែលធនាគាយើង ជាប់កាតព្វកិច្ចកាត់ទុកនូវប្រាក់ពន្ធកាត់ទុក ទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម លោកអ្នកត្រូវទូទាត់សងជូនធនាគារយើងដោយគ្មានលក្ខខណ្ឌ នូវរាល់ចំនួនទឹកប្រាក់ពន្ធដែលដល់កំណត់ត្រូវបង់ ទៅតាមការទាមទាររបសធនាគារយើង។

៣.២.៦. ប្រសិនបើ នៅកាលបរិច្ឆេទដែលត្រូវធ្វើការទូទាត់ប្រាក់ នៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មធនាគារយើងមិនអាចធ្វើការទូទាត់ប្រាក់នៅក្នុងរូបិយវត្ថុ ដូចមានកំណត់ក្នុងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មនោះ ដោយមូលហេតុមានឧបសគ្គដែលហួសពីភាពអាចគ្រប់គ្រងបានរបស់ធនាគារយើង ឬមានភាពខុសច្បាប់ក្នុងការទូទាត់ប្រាក់ក្នុងរូបិយវត្ថុដែលបានកំណត់នោះ នៅក្រោមច្បាប់ជាធរមាននៅទីកន្លែងដែលត្រូវធ្វើការទូទាត់ប្រាក់ ធនាគារយើងត្រូវធ្វើការទូទាត់ប្រាក់ក្នុងរូបិយវត្ថុ ដែលត្រូវបានតម្រូវឬអនុញ្ញាតដោយច្បាប់នៃទីកន្លែងដែលត្រូវធ្វើការទូទាត់ប្រាក់ ទោះបីជាផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មចែងថា ការទូទាត់ប្រាក់អាចត្រូវបានធ្វើតែក្នុងរូបិយវត្ថុដែលមានចែងក្នុងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មក៏ដោយ។ នៅក្នុង

ករណីនេះ អ្នកទទួលផលត្រូវបានចាត់ទុកថា បានយល់ព្រមនិងទទួលយក ការទូទាត់ប្រាក់នៅក្នុងរូបិយវត្ថុដែលត្រូវបានអនុញ្ញាតដោយច្បាប់នោះ។ លោកអ្នក យល់ និងព្រមទទួលយក នូវរាល់ហានិភ័យទាំងអស់ ដែលកើតចេញពី ឬទាក់ទងនឹងការប្រើប្រាស់រូបិយវត្ថុមួយនៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ដែលការទូទាត់ប្រាក់ដែលលោកអ្នកត្រូវទទួលបាន នឹងត្រូវបានធ្វើឡើងក្នុងរូបិយវត្ថុមួយផ្សេងទៀត រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ ហានិភ័យទាក់ទងនឹងអតិផរណានៃរូបិយវត្ថុ។ លោកអ្នក យល់ព្រមបន្ថែមទៀតថា ទាក់ទងនឹងការទូទាត់ប្រាក់ឆ្លងរូបិយវត្ថុ ធនាគារយើងមានសិទ្ធិក្នុងការអនុវត្តអត្រាប្ដូរប្រាក់នៅកាលបរិច្ឆេទដែលការទូទាត់ប្រាក់ត្រូវបានធ្វើ។

៣.៣. **ការកាត់កង៖** នៅគ្រប់ពេលវេលាទាំងអស់ បន្ទាប់ពីលោកអ្នកខកខានក្នុងការទូទាត់ប្រាក់ជូនធនាគារយើង នូវចំនួនទឹកប្រាក់ដែលលោកអ្នកជំពាក់ធនាគារយើង លោកអ្នកយល់ព្រមផ្ដល់ជូន ធនាគារយើងដោយគ្មានលក្ខខណ្ឌនិងដោយមិនអាចដកហូតវិញបាន នូវសិទ្ធិកាត់កងដែលតាមរយៈនេះ ធនាគារយើងខ្ញុំមានសិទ្ធិកាត់ទឹកប្រាក់ដែលលោកអ្នកនៅជំពាក់ធនាគារយើងនៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មដែលបានផ្ដល់ជូន ដោយផ្ទាល់និងដោយស្វ័យប្រវត្តិ ចេញពីគណនីដែលត្រូវបានកំណត់ ឬគណនីណាមួយផ្សេងទៀត ឬកាត់កងជាមួយឥណទាន ទ្រព្យធានា ដែលមានក្នុងការកាន់កាប់ ការគ្រប់គ្រង ការរក្សា ឬការគ្រប់គ្រងជាបណ្ដោះអាសន្ន នាពេលបច្ចុប្បន្ន ឬនាពេលក្រោយ របស់ធនាគារយើង ដោយមិនចាំបាច់មានការទាមទារ ឬការជូនដំណឹង បន្ថែមឡើយ។ សិទ្ធិរបស់ធនាគារយើង ដែលមាននៅក្រោមប្រការនេះអាចអនុវត្តបាន រវាងគណនីពីរឬច្រើន និងទោះបីជាគណនីណាមួយរបស់លោកអ្នក ត្រូវបានកាន់កាប់ដោយលោកអ្នករួមជាមួយបុគ្គលដទៃណាមួយក៏ដោយ។

## ៤. ប្រាតិភោគ

៤.១. តាមការតម្រូវរបស់ធនាគារយើង លោកអ្នកត្រូវផ្ដល់ជូនធនាគារយើង នូវទ្រព្យធានា និងទ្រព្យធានាបន្ថែម ដើម្បីធានាលើការទូទាត់ប្រាក់ទាំងឡាយ ដែលលោកអ្នកជំពាក់ធនាគារយើង រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ កម្រៃសេវា សោហ៊ុយចំណាយផ្សេងៗ និងចំណាយដែលកើន រហូតដល់ពេលដែលធនាគារយើង រួចផុតពីការទទួលខុសត្រូវទាំងអស់របស់ខ្លួនដែលមាននៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម តាមរយៈការអនុវត្តកិច្ចព្រមព្រៀងប្រតិភោគដែលពាក់ព័ន្ធ។ ទ្រព្យធានាអាចជា គណនីរបស់លោកអ្នកឬរបស់តតិយជនណាមួយដែលត្រូវបានបើកនិងរក្សាជាមួយធនាគារយើង ឬចលនវត្ថុដែលជាកម្មសិទ្ធិរបស់លោកអ្នកឬតតិយជនណាមួយ ឬកម្រិតឥណទាននិងឥណទាន ដែលលោកអ្នកទទួលបានក្រោមការអនុម័តយល់ព្រមដោយធនាគារយើង ដែលតាមរយៈនោះផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មត្រូវបានផ្ដល់ជូន។

៤.២. ទ្រព្យធានាដែលត្រូវបានប្រើប្រាស់ជាប្រាតិភោគ និងកាន់កាប់ដោយធនាគារយើង នឹងត្រូវបានប្រគល់ត្រឡប់ទៅឱ្យកម្មសិទ្ធិករចុះបញ្ជីនៃទ្រព្យនោះវិញ ក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃចុងក្រោយដែលធនាគារយើងបានទទួលការទាមទារឱ្យទូទាត់ប្រាក់ ឬបន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពនៃលិខិតធានាធនាគារ (ប្រសិនបើមិនមានការទាមទារឱ្យទូទាត់ប្រាក់ណាមួយកើតឡើង) ក្នុងករណីដែលធនាគារយើងទទួលបាននូវលិខិតធានាធនាគារចុងក្រោយច្បាប់ដើមដោយផ្ទាល់ពីអ្នកទទួលផល ភ្ជាប់ជាមួយលិខិតយល់ព្រមរបស់អ្នកទទួលផលដែលដោះលែងធនាគារយើងឱ្យរួចផុតពីការទទួលខុសត្រូវទាំងអស់របស់ធនាគារយើងដែលមាននៅក្រោមលិខិតធានាធនាគារ ដែលអាចទទួលយកបានដោយធនាគារយើង ហើយទឹកប្រាក់ទាំងអស់ដែលលោកអ្នកជំពាក់ធនាគារយើងនៅក្រោមលិខិតធានាធនាគារ ត្រូវបានទូទាត់សងធនាគារយើងរួចរាល់ ត្រឹមត្រូវ និងគ្រប់ចំនួន ដោយលោកអ្នក។

## ៥. ការទទួលខុសត្រូវរបស់ ធនាគារ ព្រីនស៍

៥.១. ទោះក្នុងករណីណាក៏ដោយ ក៏ការទទួលខុសត្រូវសរុបរបស់ធនាគារយើង ដែលមាននៅក្រោមឬទាក់ទងនឹងបញ្ញត្តិនិងលក្ខខណ្ឌនេះ មិនត្រូវលើសពីចំនួនសរុបនៃ កម្រៃសេវានិងសោហ៊ុយចំណាយផ្សេងៗ ដែលលោកអ្នកបានបង់ជូនធនាគារយើង នៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះឡើយ ទោះបីការទទួលខុសត្រូវនេះកើតចេញពីការបំពាន អំពើអនីត្យានុកូល(រួមបញ្ចូលទាំងការធ្វេសប្រហែស) ឬផ្សេងពីនេះ។ ធនាគារយើងមិនត្រូវទទួលខុសត្រូវលើការខាតបង់ប្រាក់ចំណេញ ការបាត់បង់ចំណូល ឬការបាត់ឱកាសធ្វើពាណិជ្ជកម្ម ឬការខូចខាតកេរ្តិ៍ឈ្មោះជំនួញ ឬការខូចខាតដោយប្រយោល ឬការខូចខាតពិសេសណាមួយឡើយ។

៥.២. ធនាគារយើង មិនមានការទទួលខុសត្រូវលើសកម្មភាព ឬអកម្មភាពណាមួយ ទាក់ទងនឹងការផ្តល់ជូនផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ដែលត្រូវបានធ្វើឡើងដោយសុចរិត និងដោយអនុលោមតាមបញ្ញត្តិច្បាប់ជាធរមាន និងការអនុវត្តជាស្តង់ដារអន្តរជាតិដែលមានក្នុងវិស័យនេះឡើយ។

៥.៣. ការផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មដោយធនាគារយើង នៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ មានភាពឯករាជ្យទាំងស្រុង ពីទំនាក់ទំនងរបស់លោកអ្នកនៅក្រោមកិច្ចសន្យាចំបង។ ធនាគារយើងពិនិត្យតែទៅលើឯកសារ មិនពិនិត្យលើទំនិញ ឬសេវា ឬការអនុវត្តដែលទាក់ទងនឹងឯកសារឡើយ។

៥.៤. លោកអ្នក យល់ព្រមថា រាល់ការណែនាំ/បញ្ជានិងទំនាក់ទំនង ដែលទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មដែលបានផ្តល់ជូននឹងត្រូវបានផ្ញើ ដោយលោកអ្នកជាអ្នករ៉ាប់រងហានិភ័យទាំងឡាយដែលមានទាក់ទងនឹងការផ្ញើនោះ។

៥.៥. លោកអ្នកយល់ព្រមថា ធនាគារយើង ធនាគារទំនាក់ទំនង និង/ឬភ្នាក់ងាររបស់ធនាគារយើង មិនទទួលខុសត្រូវលើ៖

៥.៥.១. ប្រសិទ្ធភាពនៃឯកសារ រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ៖

ក. ទម្រង់ ភាពគ្រប់គ្រាន់ ភាពពិតប្រាកដ ភាពត្រឹមត្រូវ ការក្លែងបន្លំ អានុភាពផ្លូវច្បាប់នៃហត្ថលេខាឬឯកសារណាមួយដែលត្រូវបានបង្ហាញមកកាន់ធនាគារយើង។

ខ. សេចក្តីថ្លែងការណ៍រួម ឬជាក់លាក់ណាមួយ ដែលត្រូវបានធ្វើនៅក្នុង ឬលើឯកសារណាមួយដែលត្រូវបានបង្ហាញមកកាន់ធនាគារយើង។

គ. ការពណ៌នា គុណភាព ទំងន់ បរិមាណ លក្ខខណ្ឌ ការវេចខ្ចប់ ការដឹកជញ្ជូន តម្លៃ ឬអត្ថិភាព នៃទំនិញ សេវា ឬការអនុវត្តផ្សេងទៀត ឬទិន្នន័យដែលតំណាងដោយ ឬត្រូវបានយោងនៅក្នុងឯកសារណាមួយដែលត្រូវបានបង្ហាញជូនធនាគារយើង។

ឃ. សុចរិតភាព សកម្មភាព អកម្មភាព ក្ស័យធនភាព ការអនុវត្ត ឬជំហររបស់បុគ្គលណាមួយ ដែលបានចេញ ឬត្រូវបានយោង នៅក្នុងសមត្ថភាព ឬឯកសារណាមួយ ដែលត្រូវបានបង្ហាញមកកាន់ធនាគារយើង។

៥.៥.២. ឯកសារ ឬវត្ថុ ណាមួយ ដែលមាននៅក្នុងការកាន់កាប់របស់ធនាគារយើង។

៥.៥.៣. ផលវិបាកនៃការភាន់ច្រលំ អំពើអកម្ម ការយឺតយ៉ាវ បរាជ័យ ការបាត់បង់ក្នុងអំឡុងពេលបញ្ជូន ការភាន់ច្រលំក្នុងការបកប្រែ ការកែប្រែ ការខូចខាត ការបំផ្លិចបំផ្លាញ ការកាត់ផ្តាច់ ឬការភាន់ច្រលំផ្សេងទៀតដែលកើតចេញពីការបញ្ជូនឬការប្រគល់សារឬផ្សេងពីនេះ លិខិត ឯកសារ វូបិយាណត្តិ ឬការទូទាត់ប្រាក់ដែលត្រូវបានធ្វើឡើង ឬទទួលដោយការផ្ញើ សារ(mail) ទូរសារ អ៊ីម៉ែល ស្វីហ្វ(SWIFT) ឬផ្សេងពីនេះ ទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ឬការទំនាក់ទំនងផ្សេងទៀត។

៥.៥.៤. ការប្រើប្រាស់សេវារបស់ភាគីផ្សេងទៀតដោយធនាគារយើង សម្រាប់គោលបំណងនៃការអនុវត្តតាមសេចក្តីណែនាំ/ការបញ្ជា ឬសំណើសុំរបស់លោកអ្នក។

៥.៥.៥. អត្ថិភាព លក្ខណៈ ការពណ៌នា បរិមាណ គុណភាព ទំងន់ លក្ខខណ្ឌ ការវេចខ្ចប់ តម្លៃ ឬការប្រគល់ ទំនិញ ដែលត្រូវបានអះអាងថាត្រូវបានតំណាងដោយឯកសារដែលពាក់ព័ន្ធ។

៥.៥.៦. ភាពខុសគ្នានៅក្នុង លក្ខណៈ ការពណ៌នា បរិមាណ គុណភាព ទំងន់ លក្ខខណ្ឌ ឬតម្លៃនៃទំនិញ ដែលមានជាក់ស្តែងនៅក្នុងឯកសារនោះ។

៥.៥.៧. ពេលវេលា ទីកន្លែង ការបញ្ជា ឬរបៀបដែលការដឹកជញ្ជូនត្រូវបានធ្វើឡើង ការដឹកជញ្ជូនដោយផ្នែក ឬមិនពេញលេញ ឬបរាជ័យ ឬការមិនធ្វើសកម្មភាពក្នុងការដឹកជញ្ជូនទំនិញណាមួយ ឬទាំងអស់។

៥.៥.៨. លក្ខណៈ ភាពគ្រប់គ្រាន់ សុពលភាព ឬភាពត្រឹមត្រូវ នៃការធានារ៉ាប់រងណាមួយ ក្ស័យធនភាព ឬការទទួលខុសត្រូវរបស់អ្នកធានារ៉ាប់រងណាមួយ ឬហានិភ័យណាមួយ ទាក់ទងនឹងការធានារ៉ាប់រង។

៥.៥.៩. ការបែរចេញពីការណែនាំ/បញ្ជា ការពន្យា ការបំពានលក្ខខណ្ឌ ឬការបន្លំ ដោយអ្នកដឹកទំនិញ ឬបុគ្គលដទៃណាមួយ ទាក់ទងនឹងទំនិញ ឬការដឹកទំនិញ។

៥.៥.១០. ក្ស័យធនភាព ការទទួលខុសត្រូវ ឬទំនាក់ទំនងជាមួយទំនិញរបស់បុគ្គលណាមួយ ដែលចេញលិខិតណាមួយទាក់ទងនឹងទំនិញ។

៥.៥.១១. ការយឺតយ៉ាវឬការខកខាន នៃការមកដល់នៃទំនិញឬឯកសារណាមួយឬទាំងអស់ដែលពាក់ព័ន្ធ ឬក្នុងការប្រគល់ការជូនដំណឹងពីការមកដល់នៃការជូនដំណឹងណាមួយ។

៥.៥.១២. ការបំពានលក្ខខណ្ឌនៃកិច្ចសន្យាណាមួយ រវាងអ្នកដឹកទំនិញ ឬអ្នកលក់ ឬលោកអ្នក។

៥.៥.១៣. ការខកខាននៃការយោងរបស់រូបិយាណត្តិណាមួយ ទៅនឹងលិខិតឥណទាន ឬលិខិតឥណទានប្រចាំការដែលពាក់ព័ន្ធ ឬការខកខាននៃឯកសារភ្ជាប់ជាមួយរូបិយាណត្តិដែលត្រូវចរាចរណាមួយ ឬការខកខានរបស់បុគ្គលណាមួយក្នុងការផ្ញើឯកសារ ដែលត្រូវបានតម្រូវដោយលក្ខខណ្ឌនៃលិខិតឥណទាន ឬលិខិតឥណទានប្រចាំការដែលមិនមែនជារូបិយាណត្តិ ឬការខកខានរបស់បុគ្គលណាមួយ ក្នុងការសរសេរចំនួនទឹកប្រាក់ណាមួយនៃរូបិយាណត្តិ នៅផ្នែកម្ខាងទៀតនៃលិខិតឥណទាន ឬលិខិតឥណទានប្រចាំការ ឬលះបង់ ឬទទួលយក លិខិតឥណទាន ឬលិខិតឥណទានប្រចាំការ។

៥.៦. ដើម្បីចៀសវាងរាល់មន្ទិលសង្ស័យ ធនាគារយើង និងភ្នាក់ងាររបស់ខ្លួន មិនត្រូវទទួលខុសត្រូវលើរាល់ការចំណាយដែលកើតចេញពី៖

៥.៦.១. ធនាគារយើងធ្វើសកម្មភាពដោយស្របតាមបញ្ញត្តិច្បាប់ជាធរមាន ។

៥.៦.២. ធនាគារយើងធ្វើសកម្មភាព ស្របតាមកិច្ចព្រមព្រៀងដែលធនាគារយើងមានជាមួយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតទាក់ទងនឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយគ្រឹះស្ថានទាំងនោះ ទោះបីជាលោកអ្នកអាចផ្ដល់ការណែនាំ/បញ្ជាដែលមានខ្លឹមសារផ្ទុយក៏ដោយ។

៥.៦.៣. ករណីដែលហួសពីការគ្រប់គ្រងរបស់ធនាគារយើង ឬភ្នាក់ងាររបស់ធនាគារយើង រាប់បញ្ចូលទាំង សកម្មភាពភាពអកម្ម ឬការបំពានលក្ខខណ្ឌ ប្រព្រឹត្តដោយធនាគារទំនាក់ទំនង ធនាគារប្រមូលឯកសារ ឬធនាគារទូទាត់ប្រាក់។

៥.៧. លោកអ្នកយល់ព្រមថា លោកអ្នកទទួលខុសត្រូវទាំងស្រុងក្នុងការ៖

៥.៧.១. ធានាលើ ភាពច្បាស់លាស់ ភាពអាចអនុវត្តបាន ឬប្រសិទ្ធភាពនៃលក្ខខណ្ឌ ឬតម្រូវការដែលមានចែងក្នុងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម និង

៥.៧.២. គោរពតាមបញ្ញត្តិច្បាប់ជាធរមានទាំងអស់ ទាក់ទងនឹងកិច្ចសន្យាចំបង ដែលផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មមានទំនាក់ទំនងជាមួយ និងទទួលបាននូវរាល់ឯកសារចាំបាច់ និងការអនុម័តយល់ព្រមនានា ពីអង្គភាពរដ្ឋាភិបាលឬនិយ័តករ និងផ្ដល់ជូនធនាគារយើងនូវឯកសារនិងការអនុម័តយល់ព្រមទាំងនោះ ទៅតាមការស្នើសុំរបស់ធនាគារយើង។ ធនាគារយើងមិនទទួលខុសត្រូវក្នុងការផ្ដល់ការប្រឹក្សាយោបល់ និងមិនមានភារកិច្ចណាមួយក្នុងការផ្ដល់យោបល់ជូនលោកអ្នកលើបញ្ហានេះឡើយ។

៥.៨. លោកអ្នកយល់ព្រមថា ធនាគារយើងមិនទទួលខុសត្រូវក្នុងការទូទាត់ជូនលោកអ្នក ឬប្រសិនបើបានទូទាត់ជូនលោកអ្នករួចហើយ លោកអ្នកត្រូវប្រគល់ប្រាក់ដែលបានទូទាត់រួចនោះ រួមទាំងការប្រាក់ កម្រៃសេវា និងសោហ៊ុយចំណាយដែលបានចំណាយជូនធនាគារយើងវិញ ទៅតាមការទាមទាររបស់ធនាគារយើង ប្រសិនបើ៖

ក. មានការក្លែងបន្លំ ភាពខុសច្បាប់ ឬសកម្មភាពដែលមិនត្រូវបានអនុញ្ញាតប្រព្រឹត្តដោយបុគ្គលណាមួយ (ដែលមិនមែនជាធនាគារយើង) ទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ឬ

ខ. មានការមិនព្រមទូទាត់ប្រាក់ណាមួយជូនធនាគារយើងដោយបុគ្គលណាមួយ ឬ ធនាគារយើងត្រូវបានតម្រូវឱ្យធ្វើការទូទាត់សងប្រាក់ជូនទៅបុគ្គលណាមួយ នូវប្រាក់ដែលធនាគារយើងបានទទួល ទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ដោយសារ៖

i វិវាទពាណិជ្ជកម្ម រវាងលោកអ្នក និងបុគ្គលដទៃណាមួយ ឬ

ii ដីកាសម្រេចរក្សាការពារណាមួយ ឬសេចក្ដីបង្គាប់ឱ្យបញ្ឈប់ការទូទាត់ប្រាក់ ឬសេចក្ដីបង្គាប់ផ្សេងទៀតរបស់តុលាការ (ទោះត្រូវបាន ឬមិនត្រូវបានលើកលែង នៅពេលបន្ទាប់) ។

លោកអ្នក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ធនាគារយើង ប្រសិនបើលោកអ្នកដឹងពីអត្ថិភាព នៃកាលៈទេសៈណាមួយដូចមានរៀបរាប់ខាងលើ បានកើតឡើង ឬអាចនឹងកើតឡើង រួមជាមួយព័ត៌មានលម្អិតនៃកាលៈទេសៈនោះផង។

៥.៩. លោកអ្នកយល់ព្រមថា ធនាគារយើងមិនទទួលខុសត្រូវ លើការស៊ើបអង្កេតលើភាពត្រឹមត្រូវនៃការណែនាំ/បញ្ជាណាមួយ ដែលធនាគារយើងបានទទួល ឬលើយថាភូតភាពនៃហត្ថលេខាណាមួយ ឬការអនុញ្ញាត (អេឡិចត្រូនិច ឬផ្សេងពីនេះ) ដែលមានលើការណែនាំ/បញ្ជានោះ ឬលើហត្ថលេខីឬអ្នកទទួលបានការអនុញ្ញាតដែលកាន់កាប់ឋានៈ តួនាទីការិយាល័យ ឬមុខតំណែងណាមួយ ដែលនៅក្នុងការណែនាំ/បញ្ជានោះបុគ្គលនោះទាមទារឬអះអាងលើការកាន់កាប់នោះ។

៥.១០. លោកអ្នកយល់ព្រមបន្ថែមទៀតថា ធនាគារយើង មិនទទួលខុសត្រូវលើការផ្តល់ជូនផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ ដែលត្រូវបាន កាត់ផ្តាច់ រារាំង ពន្យា ឬទទួលរងការប៉ះពាល់ជាអវិជ្ជមានផ្សេងទៀត ទាំងស្រុង ឬដោយផ្នែក ដោយសារបញ្ញត្តិច្បាប់ជាធរមានណាមួយឡើយ។

## ៦. សំណងការខូចខាត

៦.១. លោកអ្នកយល់ព្រម សងសំណងការខូចខាត និងទូទាត់សងធនាគារយើង ទៅតាមការទាមទាររបស់ធនាគារយើង និងធានាថាធនាគារយើង ធនាគារទំនាក់ទំនង ភ្នាក់ងារ បុគ្គលិក ម្ចាស់ភាគហ៊ុន និងអភិបាលរបស់ធនាគារយើង ពុំទទួលរងផលប៉ះពាល់ពីបណ្តឹងណាមួយ ឬត្រូវចៀសផុតពីវិធានការផ្លូវច្បាប់ផ្សេងៗ និងរាល់ការខាតបង់ បណ្តឹងទាមទារ បំណុល ការខូចខាត កម្រៃ និងការចំណាយផ្សេងៗទៀត ការផាកពិន័យ រួមទាំងកម្រៃសេវាមេធាវី ដោយផ្ទាល់ ឬដោយប្រយោល ដែលកើតចេញពី ឬទាក់ទងនឹង ការផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម អនុលោមភាពរបស់ធនាគារយើង ទៅនឹងការណែនាំ/បញ្ជារបស់លោកអ្នក ឬការណែនាំ/បញ្ជាដែលហាក់ត្រូវបានធ្វើឡើងដោយលោកអ្នក ទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ការប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មរបស់លោកអ្នក ការផ្តល់ព័ត៌មាននិងឯកសារទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មរបស់លោកអ្នក ការធានាអះអាង និងការបំពានបញ្ញត្តិណាមួយរបស់លោកអ្នក លើបញ្ញត្តិនិងលក្ខខណ្ឌនេះ ឬឯកសារហិរញ្ញប្បទានពាណិជ្ជកម្ម ឬបញ្ញត្តិច្បាប់ជាធរមាន។

៦.២ សំណងការខូចខាតដែលមាននៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវជាកាតព្វកិច្ចបន្ត ដាច់ដោយឡែក និងឯករាជ្យ ពីកាតព្វកិច្ចផ្សេងទៀតរបស់លោកអ្នក ហើយត្រូវបន្តមានអានុភាពអនុវត្ត ទោះបីជា ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មត្រូវបានបញ្ចប់ ឬបំពេញចប់សព្វគ្រប់ក៏ដោយ។

## ៧. បញ្ញត្តិទូទៅ

### ៧.១. ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងទណ្ឌកម្ម

៧.១.១. ទោះបីជាមានចែងផ្សេងពីនេះ ដោយប្រការណាមួយ នៅក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះក៏ដោយ ក៏ធនាគារយើងមិនមានកាតព្វកិច្ចក្នុងការធ្វើ ឬមិនធ្វើសកម្មភាពណាមួយ ប្រសិនបើធនាគារយើងយល់ឃើញដោយសមស្របថា ប្រសិនបើខ្លួនធ្វើឬមិនធ្វើសកម្មភាពនោះ អាចនឹងបង្កើតឱ្យមានការបំពានច្បាប់ និងបទប្បញ្ញត្តិជាធរមាន ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬច្បាប់ ឬបទប្បញ្ញត្តិស្តីពីទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ដែលកំពុងអនុវត្តចំពោះធនាគារយើង។

៧.១.២. លោកអ្នកត្រូវផ្តល់ជូនធនាគារយើងភ្លាមៗ ទៅតាមការតម្រូវ នូវព័ត៌មាននិងឯកសារដែលពាក់ព័ន្ធ និងដែលកំពុងស្ថិតក្នុងការកាន់កាប់ ការរក្សាទុក ឬការគ្រប់គ្រងរបស់លោកអ្នក ដើម្បីអនុញ្ញាតឱ្យធនាគារយើងអាចប្រតិបត្តិដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានណាមួយ ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងច្បាប់ឬបទប្បញ្ញត្តិជាធរមាន ស្តីពីទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ដែលកំពុងអនុវត្តចំពោះធនាគារយើង។

៧.១.៣. លោកអ្នកយល់ព្រម អនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់លោកអ្នក ដែលមាននៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ ដោយអនុលោមតាម ច្បាប់និងបទប្បញ្ញត្តិជាធរមាន ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងច្បាប់ឬបទប្បញ្ញត្តិជាធរមាន ស្តីពីទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ដែលកំពុងអនុវត្តចំពោះធនាគារយើង។

៧.១.៤. លោកអ្នកប្រកាសថា លោកអ្នកធ្វើសកម្មភាពនៅក្នុងនាមរបស់លោកអ្នកផ្ទាល់ ហើយលោកអ្នកមិនមែនជាអាណត្តិគាហក ឬមានសមាសភាពជាភ្នាក់ងារ លើកលែងតែលោកអ្នកបានបើកបង្ហាញជូន ធនាគារយើងដោយច្បាស់លាស់ និងជាក់លាក់ផ្សេងពីនេះ។

### ៧.២. ការធានាអះអាង

៧.២.១. លោកអ្នក ធានាអះអាងចំពោះធនាគារយើងថា៖

ក. លោកអ្នកគឺជានីតិបុគ្គលដែលត្រូវបានបង្កើតឡើង អនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬច្បាប់បរទេសណាមួយ និងមានអំណាចក្នុងការប្រតិបត្តិអាជីវកម្មបច្ចុប្បន្នរបស់ខ្លួន ។

ខ. លោកអ្នកបាននិងត្រូវអនុលោមតាមបញ្ញត្តិច្បាប់ជាធរមានទាំងអស់ ដែលទាក់ទងនឹងទំនិញ សេវា ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងបញ្ញត្តិច្បាប់ជាធរមានដទៃទៀត ។

គ. លោកអ្នកមានអំណាចនិងសមត្ថភាពពេញលេញ ក្នុងការបង្កើតនិងអនុវត្តកាតព្វកិច្ចរបស់លោកអ្នក ដែលមាននៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ ។

ឃ. លោកអ្នកបានធ្វើរាល់សកម្មភាពចាំបាច់នានា និងទទួលបានការអនុញ្ញាតដែលត្រូវបានតម្រូវពីក្រុមប្រឹក្សាភិបាល និង/ឬម្ចាស់ភាគហ៊ុន ដើម្បីអនុញ្ញាតឱ្យលោកអ្នកអាច បង្កើត ប្រគល់ អនុវត្ត កាតព្វកិច្ច និងប្រតិបត្តិការដែលត្រូវធ្វើរបស់លោកអ្នក នៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ ហើយការអនុញ្ញាតទាំងនេះមានប្រសិទ្ធភាពអនុវត្តពេញលេញ ។

ង. ការអនុវត្តកាតព្វកិច្ចរបស់លោកអ្នក នៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ នឹងមិនមានទំនាស់ជាមួយ ច្បាប់ បញ្ញត្តិ ការព្រមព្រៀង ការរៀបចំនៃលិខិតូបករណ៍ ដែលភ្ជាប់កាតព្វកិច្ចលើលោកអ្នក ឬទ្រព្យសម្បត្តិរបស់លោកអ្នកឡើយ ។

ច. ព័ត៌មាននិងឯកសារទាំងអស់ ដែលលោកអ្នកបានផ្តល់ជូនធនាគារយើង មានសុពលភាព ពិតប្រាកដ និងត្រឹមត្រូវដោយមិនមានវិការៈ ។

ឆ. លោកអ្នកមិនត្រូវប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម សម្រាប់គោលបំណងខុសច្បាប់ ឬមិនត្រូវបានអនុញ្ញាតដោយបញ្ញត្តិនិងលក្ខខណ្ឌនេះ ទោះបីមានចែងដោយជាក់ច្បាស់ ឬដោយបង្កប់ន័យក៏ដោយ ឬដោយច្បាប់ ឬបញ្ញត្តិដែលកំពុងមានប្រសិទ្ធិភាពអនុវត្ត ឡើយ ។ និង

ជ. លោកអ្នកត្រូវធ្វើការបញ្ជា ប្រតិបត្តិការ ឬសកម្មភាពនីមួយៗ ដែលត្រូវបានទទួលដោយធនាគារយើង និង/ឬដែលមានពាក់ព័ន្ធជាមួយលោកអ្នក ក្នុងការប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម ដោយសុចរិត ។

## ៧.៣. ព័ត៌មានសម្ងាត់ និងការបញ្ចេញព័ត៌មានសម្ងាត់

៧.៣.១. ធនាគារយើង នឹងរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ព័ត៌មានដែលទាក់ទងនឹងគណនី/ប្រតិបត្តិការដែលត្រូវបានធ្វើឡើង នៅក្រោមការផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងរាល់ព័ត៌មានដែលទាក់ទងឯទៀតជាការសម្ងាត់បំផុត។ ប៉ុន្តែ លោកអ្នកអនុញ្ញាតដោយគ្មានលក្ខខណ្ឌនិងដោយមិនអាចដកហូតវិញបាន ឱ្យធនាគារយើងបង្ហាញព័ត៌មានទាំងនោះ៖

ក. ទៅកាន់ការិយាល័យ សាខា បុត្រសម្ព័ន្ធ បុគ្គលិក ឬភ្នាក់ងាររបស់ធនាគារយើង។

ខ. ទៅកាន់សវនករ អ្នកប្រឹក្សាយោបល់វិជ្ជាជីវៈ អ្នកផ្តល់សេវាតតិយភាគី ធនាគារទំនាក់ទំនង អ្នកដំណើរការតតិយភាគី ឬដៃគូអាជីវកម្មរបស់ ធនាគារយើង ក្រោមកាតព្វកិច្ចរក្សាការសម្ងាត់ចំពោះធនាគារយើង។

គ. ទៅកាន់បុគ្គលណាមួយ និយ័តករ និងអាជ្ញាធរដែលមានសមត្ថកិច្ចផ្សេងទៀត ដែលត្រូវបានតម្រូវឱ្យបង្ហាញព័ត៌មាន ស្របតាមសេចក្តីបង្គាប់របស់តុលាការ ឬការបញ្ជាដែលចេញពីយុត្តាធិការដែលអនុវត្តណាមួយ ឬអនុលោមតាមបញ្ញត្តិច្បាប់ជាធរមាន។

ឃ. ដើម្បីផ្ទៀងផ្ទាត់ និងអនុវត្តសិទ្ធិដែលមានក្នុងកិច្ចសន្យា ឬគោលនយោបាយដែលអនុវត្តផ្សេងទៀត របស់ធនាគារយើង។

ង. ដើម្បីរកឱ្យឃើញ និងការពារ ប្រឆាំងនឹងការបោកបន្លំ ឬភាពទន់ខ្សោយនៃបច្ចេកទេស ឬសុវត្ថិភាព។ ឬ

ច. ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់ណាមួយដែលធនាគារយើងយល់ឃើញថាសមស្រប។

៧.៣.២. លោកអ្នកយល់ព្រមបន្ថែមទៀតថា ប្រសិនបើមានការបំពានលើព័ត៌មានសម្ងាត់របស់លោកអ្នក ដោយភាគីទីបីណាមួយ ដោយមិនមានកំហុសរបស់ធនាគារយើង លោកអ្នកយល់ព្រមឱ្យធនាគារយើង រួចផុតពីការទទួលខុសត្រូវនានាដែលកើតចេញពីការបំពាននោះ។

៧.៣.៣. ធនាគារយើងមិនទទួលខុសត្រូវលើ ការសម្ងាត់ ឬសុវត្ថិភាពនៃសារទំនាក់ទំនងនានា ទោះបីត្រូវបានបញ្ជូនដោយផ្ទាល់ ឬតាមមធ្យោបាយផ្សេងទៀត នៅក្នុងអំឡុងពេលនៃការផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មដោយធនាគារយើង និងដំណើរការនៃប្រព័ន្ធនិងណែតវើក ដែលបណ្តាលឱ្យមានការបាត់បង់ ឬការខូចខាតណាមួយដល់លោកអ្នក ឬបុគ្គលណាមួយ ទាក់ទងនឹងការផ្តល់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មនេះឡើយ។

៧.៤. **ការជូនដំណឹង**

៧.៤.១. រាល់ការជូនដំណឹងដែលត្រូវបានតម្រូវ ឬអនុញ្ញាតឱ្យមាន ត្រូវបានសន្មត់ថាបានប្រគល់ជូនធនាគារយើង អ្នកទទួលផល ឬលោកអ្នក ដោយត្រឹមត្រូវ ប្រសិនបើបានប្រគល់ជូន នៅអាសយដ្ឋានផ្លូវការរបស់ភាគីដូចមានបញ្ជាក់នៅក្នុងពាក្យស្នើសុំ ។

៧.៤.២. រាល់ការជូនដំណឹង ត្រូវចាត់ទុកថាបានប្រគល់ជូនត្រឹមត្រូវ៖

ក. នៅកាលបរិច្ឆេទប្រគល់ ប្រសិនបើត្រូវបានប្រគល់ដោយផ្ទាល់ ។

ខ. នៅកាលបរិច្ឆេទផ្ញើ ប្រសិនបើផ្ញើតាមសំបុត្រ ។

គ. នៅពេលភាគីផ្ញើទទួលបានលិខិតបញ្ជាក់ថាបានបញ្ជូនបានសម្រេច ប្រសិនបើផ្ញើតាមទូរសារ ។

ឃ. នៅពេលផ្ញើចេញ ហើយភាគីផ្ញើមិនបានទទួលអ៊ីម៉ែល ដែលបញ្ជាក់ពីបរាជ័យនៃការបញ្ជូនសារ ប្រសិនបើផ្ញើតាមអ៊ីម៉ែល ។

ង. ០៥(ប្រាំ)ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីផ្ញើ និងបញ្ជាក់ថាសំបុត្រដែលមានផ្ទុកលិខិតជូនដំណឹងត្រូវបានដាក់ទៅតាមអាសយដ្ឋានត្រឹមត្រូវរបស់ភាគីទទួល ត្រូវបានបោះត្រា និងផ្ញើត្រឹមត្រូវ ប្រសិនផ្ញើតាមប្រៃសណីយ៍ ។

ច. ប្រសិនបើការជូនដំណឹងត្រូវបានធ្វើឡើងតាមសំបុត្រដែលមានការបញ្ជាក់ ឬចុះបញ្ជី (ទាំងក្នុងស្រុក ឬក្រៅប្រទេស) ឬមធ្យោបាយសមមូល (បញ្ជូនត្រឡប់វិញនូវបង្កាន់ដៃស្នើសុំ) នៅកាលបរិច្ឆេទដែលសំបុត្រត្រូវបានបញ្ជូន ឬបម្រុងបញ្ជូន ។

៧.៤.៣. លោកអ្នកត្រូវជូនដំណឹងភ្លាមៗ ទៅកាន់ធនាគារយើង អំពីការផ្លាស់ប្តូរព័ត៌មានទំនាក់ទំនង និង ព័ត៌មានបង់ប្រាក់។ រហូតដល់ពេលដែលការផ្លាស់ប្តូរនោះត្រូវបានជូនដំណឹង រាល់សកម្មភាពនានាដែលធនាគារយើងបានធ្វើ ដោយផ្អែកលើព័ត៌មានទំនាក់ទំនងពីមុនដែលបានផ្តល់ជូនធនាគារយើង ត្រូវបានចាត់ទុកថាត្រឹមត្រូវ និងជាការបំពេញកាតព្វកិច្ចត្រឹមត្រូវដោយធនាគារយើង នៅក្រោមបញ្ញត្តិនិងលក្ខណ្ឌនេះ ។

៧.៥. **ប្រធានសក្តិ៖** ក្នុងករណីប្រធានសក្តិ ធនាគារយើងមិនទទួលខុសត្រូវលើផលវិបាកទាំងឡាយ ដែលកើតចេញពីការអាក់ខានដំណើរការអាជីវកម្មរបស់ធនាគារយើង ដែលបណ្តាលមកពីករណីប្រធានសក្តិឡើយ។ បន្ទាប់ពីបានបន្តដំណើរការអាជីវកម្មរបស់ខ្លួនឡើងវិញ ធនាគារយើងនឹងមិនទូទាត់សង ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយ ដែលបានផុតសុពលភាព នៅក្នុងអំឡុងពេលនៃការអាក់ខានដំណើរការអាជីវកម្មរបស់ធនាគារយើងឡើយ ។

៧.៦ **វិសោធនកម្ម៖** លោកអ្នកយល់ព្រមអនុញ្ញាតឱ្យធនាគារយើងធ្វើវិសោធនកម្មលើបញ្ញត្តិណាមួយ នៃបញ្ញត្តិនិងលក្ខខណ្ឌនេះនៅពេលណាមួយ ដោយធ្វើការជូនដំណឹងទៅកាន់លោកអ្នក តាមរយៈមធ្យោបាយជូនដំណឹងណាមួយដែលមានរបស់ធនាគារយើង រាប់បញ្ចូលទាំងការជូនដំណឹងតាមរយៈការដាក់ផ្សាយនៅលើគេហទំព័ររបស់ធនាគារយើង។ វិសោធនកម្មនោះត្រូវមានប្រសិទ្ធភាពអនុវត្ត គិតចាប់ពីកាលបរិច្ឆេទដែលមានកំណត់នៅក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ ។ លោកអ្នកយល់ព្រមថា ប្រសិនបើលោកអ្នកបន្តប្រើប្រាស់ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម បន្ទាប់ពីធនាគារយើងបានជូនដំណឹងទៅកាន់លោកអ្នកពីវិសោធនកម្មរួចហើយ ត្រូវចាត់ទុកថា លោកអ្នកយល់ព្រមទទួលយកការកែប្រែនោះ និងព្រមអនុវត្តតាមបញ្ញត្តិនិងលក្ខខណ្ឌដែលត្រូវបានធ្វើវិសោធនកម្មនោះ ។

៧.៧. **ការដោះស្រាយបណ្តឹងរបស់អតិថិជន៖** ប្រសិនបើលោកអ្នកមានការព្រួយបារម្ភ ឬបណ្តឹងណាមួយ ឬត្រូវការការពន្យល់ណាមួយ ទាក់ទងនឹងផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម លោកអ្នកអាចទាក់ទងមកកាន់សេវាអតិថិជនរបស់ធនាគារយើងតាមរយៈទូរស័ព្ទលេខ៖ **១៨០០ ២០ ៨៨៨៨** ឬអ៊ីម៉ែល៖ info@princebank.com.kh ឬគេហទំព័ររបស់ធនាគារយើង។ លោកអ្នកអាចត្រូវបានតម្រូវឱ្យផ្តល់ជូនធនាគារយើង នូវរាល់ព័ត៌មាននិងឯកសារដែលពាក់ព័ន្ធទាំងអស់ នៅពេលលោកអ្នក

ដាក់ពាក្យបណ្ដឹងមកកាន់ធនាគារយើង។ ទោះបីលោកអ្នក ជាបុគ្គលដែលបានដាក់ពាក្យបណ្ដឹងមកកាន់ធនាគារយើង ឬជាបុគ្គលដែលពាក្យបណ្ដឹងណាមួយត្រូវបានដាក់ប្រឆាំងនឹងលោកអ្នកក៏ដោយ លោកអ្នកយល់ព្រមសហការយ៉ាងពេញលេញជាមួយធនាគារយើង ដើម្បីដោះស្រាយបណ្ដឹងឬវិវាទនោះ ដូចដែលបានតម្រូវដោយសមហេតុផលដោយធនាគារយើង រាប់បញ្ចូលនិងមិនកម្រិតត្រឹមតែ ការបង្ហាញខ្លួនរបស់លោកអ្នកនៅសាខាប្រតិបត្តិការណាមួយរបស់ធនាគារយើង នៅក្នុងអំឡុងពេលដែលកំណត់ដោយធនាគារយើងនិងបានជូនដំណឹងទៅកាន់លោកអ្នក និងការផ្ដល់ជូនធនាគារយើងនូវរាល់ព័ត៌មានឬឯកសារ ទៅតាមស្នើសុំដោយសមហេតុផលរបស់ធនាគារយើង បើមិនដូច្នោះទេ ត្រូវបានចាត់ទុកថាបានយល់ព្រមនិងសុខចិត្តទទួលយកដំណោះស្រាយនៃវិវាទឬបណ្ដឹងដែលធនាគារយើងបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយ នីតិវិធីប្រតិបត្តិ និងគោលការណ៍ណែនាំផ្ទៃក្នុងដែលពាក់ព័ន្ធជាធរមានរបស់ធនាគារយើង ។

៧.៨. **ការបោះបង់សិទ្ធិ៖** គ្មានហាមឃាត់ ការធ្វេសប្រហែស ឬការបោះបង់ណាមួយ ដែលត្រូវបានធ្វើឡើងដោយ ធនាគារយើងទាក់ទងនឹងការអនុវត្ត ឬការអនុវត្តសិទ្ធិ ឬសិទ្ធិទទួលបានសំណងណាមួយ ដែលកើតចេញពី បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវធ្វើឱ្យខូចខាតដល់សិទ្ធិរបស់ធនាគារយើង ដែលមាននាពេលក្រោយក្នុងការអនុវត្តសិទ្ធិដដែលនោះឡើយ។ គ្មានការបោះបង់សិទ្ធិណាមួយរបស់ធនាគារយើង ត្រូវមានសុពលភាពឡើយ លើកលែងតែការបោះបង់នោះ ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរដោយធនាគារយើង ។

៧.៩. **ស្វ័យភាពនៃបញ្ញត្តិ៖** ប្រសិនបើបញ្ញត្តិណាមួយ នៃបញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានប្រកាសថា មិនអាចអនុវត្តបាន អសុពល ឬមិនស្របច្បាប់ បញ្ញត្តិនោះត្រូវបានចាត់ទុកថា ត្រូវបានដកចេញពីបញ្ញត្តិនិងលក្ខខណ្ឌនេះ ហើយបញ្ញត្តិដែលនៅសល់នៃបញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបន្តមានសុពលភាពអនុវត្តពេញលេញដដែល ។

៧.១០. **អនុប្បទាន៖** លោកអ្នក យល់ព្រមដោយមិនអាចដកហូតវិញបាន អនុញ្ញាតឱ្យធនាគារយើងធ្វើអនុប្បទានសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនមួយផ្នែកឬទាំងអស់ដែលមាននៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ ឬនៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយដែលត្រូវបានផ្ដល់ជូនដោយធនាគារយើង ទៅកាន់បុគ្គលណាមួយ ទៅតាមការជ្រើសរើសរបស់ធនាគារយើង នៅពេលណាមួយក៏បាន ដោយមិនចាំបាច់មានការយល់ព្រមបន្ថែមពីលោកអ្នកឡើយ ដោយធ្វើការជូនដំណឹងទៅកាន់លោកអ្នក។ លោកអ្នកយល់ព្រមបន្ថែមទៀតថា លោកអ្នកមិនអាចធ្វើអនុប្បទានសិទ្ធិនិងកាតព្វកិច្ចរបស់លោកអ្នកមួយផ្នែកឬទាំងស្រុង ដែលមាននៅក្រោមបញ្ញត្តិនិងលក្ខខណ្ឌនេះ ឬនៅក្រោមផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មណាមួយដែលត្រូវបានផ្ដល់ជូនដោយធនាគារយើងទៅបុគ្គលណាមួយ ដោយគ្មានការយល់ព្រមជាមុនពីធនាគារយើងបានឡើយ។

៧.១១. **ច្បាប់គ្រប់គ្រង និងយុត្តាធិការ៖** បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតចេញពី ឬទាក់ទងនឹងបញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវដោះស្រាយដោយសន្តិវិធីរវាងលោកអ្នកនិងធនាគារយើង បើមិនដូច្នោះទេ វិវាទនោះនឹងត្រូវបានបញ្ជូនទៅដោះស្រាយជាចុងក្រោយដោយតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**បានទទួលស្គាល់ និងយល់ព្រមដោយ៖**

ឈ្មោះ ..........................................
កាលបរិច្ឆេទ៖ ................................

## ឧបសម្ព័ន្ធ ១៖ ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងកម្រៃសេវា

| ផលិតផលនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម | កម្រៃសេវា |
|---|---|
| **លិខិតឥណទាននាំចេញ** | |
| កម្រៃសេវាប្រឹក្សា | ៤០ ដុល្លារអាមេរិក |
| កម្រៃសេវាប្រឹក្សាលើវិសោធនកម្ម | ២០ ដុល្លារអាមេរិក |
| កម្រៃសេវាត្រួតពិនិត្យឯកសារ | 0.១៨% (អប្បបរមា ៥0 ដុល្លារអាមេរិក) |
| កម្រៃសេវាផ្ញើឯកសារ | ប្រែប្រួល (៥0 ដុល្លារអាមេរិក) |
| **លិខិតឥណទាននាំចូល** | |
| កម្រៃសេវាលើការចេញលិខិតឥណទាននាំចូល (ធានាដោយសាច់ប្រាក់ ឬកម្រិតឥណទាន) | 0,១% ក្នុងមួយខែ (អប្បបរមា ២០ ដុល្លារអាមេរិក ក្នុង១ខែ) បូករួមថ្លៃសេវា cable fee ៣0 ដុល្លារអាមេរិក |
| កម្រៃសេវាលើការធ្វើវិសោធនកម្ម លើចំនួនទឹកប្រាក់ និង សុពលភាព | 0,១% ក្នុងមួយខែ (អប្បបរមា ២០ដុល្លារអាមេរិក ក្នុង១ខែ) បូករួមថ្លៃសេវា cable fee ៣0 ដុល្លារអាមេរិក |
| កម្រៃសេវាលើការធ្វើវិសោធនកម្មផ្សេងទៀត | ៥0 ដុល្លារអាមេរិក |
| កម្រៃសេវាលុបចោល | ៥0 ដុល្លារអាមេរិក |
| កម្រៃសេវាលើការធ្វើស៊ីការទទួលយកឯកសារ | 0,១% ក្នុងមួយខែ (អប្បបរមា ២០ ដុល្លារអាមេរិក ក្នុងមួយខែ) |
| កម្រៃសេវាទូទាត់ | ៣0 ដុល្លារអាមេរិក |
| កម្រៃសេវាសងប្រាក់ | ៤0 ដុល្លារអាមេរិក (កាត់ចេញពីប្រាក់ដែលត្រូវធ្វើការទូទាត់) |
| កម្រៃសេវាក្នុងករណីឯកសារមិនត្រឹមត្រូវ | ៥0 ដុល្លារអាមេរិក (កាត់ចេញពីប្រាក់ដែលត្រូវធ្វើការទូទាត់) បូកនឹង ថ្លៃសេវា cable fee ២0 ដុល្លារអាមេរិក |
| **សេវាប្រមូលឯកសារនាំចេញ** | |
| កម្រៃសេវាប្រមូលឯកសារ | 0,១% (អប្បបរមា ៤0 ដុល្លារអាមេរិក) |
| កម្រៃសេវាផ្ញើឯកសារ | ប្រែប្រួល |
| **សេវាប្រមូលឯកសារនាំចូល** | |
| កម្រៃសេវាប្រមូលឯកសារ | 0,១% (អប្បបរមា ៤0 ដុល្លារអាមេរិក) |
| កម្រៃសេវាទូទាត់ការប្រមូលឯកសារ | ៣0 ដុល្លារអាមេរិក |
| **លិខិតធានាធនាគារ / លិខិតឥណទានប្រចាំការ** | |
| កម្រៃសេវាប្រឹក្សា | ៤0 ដុល្លារអាមេរិក |
| កម្រៃសេវាប្រឹក្សាលើវិសោធនកម្ម | ២0 ដុល្លារអាមេរិក |
| កម្រៃសេវាចេញលិខិត | 0,១% ក្នុងមួយខែ (អប្បបរមា ២០ ដុល្លារអាមេរិក ក្នុងមួយខែ) |
| កម្រៃសេវាលើការធ្វើវិសោធនកម្មលើ ចំនួនទឹកប្រាក់ធានា និង សុពលភាព | 0,១% ក្នុងមួយខែ (អប្បបរមា ២០ ដុល្លារអាមេរិក ក្នុងមួយខែ) |
| កម្រៃសេវាលើការធ្វើវិសោធនកម្មផ្សេងទៀត | ៣0 ដុល្លារអាមេរិក |
| កម្រៃសេវាលុបចោល | ៥0 ដុល្លារអាមេរិក |
| កម្រៃសេវាលើការទាមទារឱ្យទូទាត់ប្រាក់ | 0,១% (អប្បបរមា ១00 ដុល្លារអាមេរិក) |
| កម្រៃសេវាលើការចេញលិខិតធានាលើការដឹកទំនិញ | 0,១% ក្នុងមួយខែ (អប្បបរមា ៥0 ដុល្លារអាមេរិក ក្នុងមួយខែ) |